# ជំពូក ១៣

# ការប្រណាំងប្រជែងរវាងសៀម និងយួន ដើម្បីត្រួតត្រាប្រទេសខ្មែរ

## (ស.វ.ទី១៨ និង ទី១៩)

លុះឃើញយួនដណ្តើមយកបានទឹកដីរបស់ខ្មែរបានជាច្រើន សៀមដែលបានចាត់ទុកថាប្រទេសខ្មែរជាសាមន្តរដ្ឋរបស់គេតាំងពីយូរយារណាស់មកហើយនោះ ក៏បានរិះរកមធ្យោបាយដើម្បីទប់ទល់នឹងការឈ្លានពានរបស់យួន ។ ដូច្នេះ ការប្រណាំងប្រជែងមួយក៏បានកើតឡើងរវាងយួន និងសៀមក្នុងការត្រួតត្រាប្រទេសខ្មែរ ។

## ក. ឥទ្ធិពលដ៏ខ្លាំងក្លារបស់យួន

ក្នុងដំណាក់ការដំបូងនេះ ឥទ្ធិពលរបស់យួនមានសភាពខ្លាំងក្លាជាងឥទ្ធិពលរបស់សៀម ព្រោះថា **ឧទ័យរាជាអង្គតន់** កាលដែលបានកំចាត់គូសត្រូវរបស់ព្រះអង្គអស់ហើយ ត្រូវបានស្តេចយួនទទួលស្គាល់អោយឡើងសោយរាជ្យនៅក្រុង **ឧដុង្គមានជ័យ** និងបានលើកអោយយួននូវដីពីខេត្ត ជាហេតុបណ្តាលអោយកម្ពុជាក្រោមទាំងមូលត្រូវធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់រាជការយួន ។

### ១. ព្រះបាទនារាយណ៍រាជាទី២ អង្គតន់ (១៧៥៨-១៧៧៥)

នៅគ.ស. ១៧៦០ ព្រះអង្គទ្រង់តាំង អ្នកម្នាងខង អោយហៅថាអ្នកម៉ែនាង **មាណាចុង្ឆាខតី** ។

នៅគ.ស.១៧៦៣ ក្រោយពីបានប្រគល់កិច្ចការរដ្ឋអោយមន្ត្រីធំៗ កាន់ហើយ ព្រះអង្គទ្រង់ចេញសាងផ្នួសបាន ៣ខែ លុះចាកសិក្ខាបទមក ទ្រង់ត្រឡប់មកសោយរាជ្យវិញ ។

ពីរឆ្នាំក្រោយមក អ្នកម៉ែនាង **មាណាចុទ្ធាខតី** ទ្រង់ប្រសូតបុត្រីនាម **អ្នកអង្គមិញ** រួចហើយត្រូវលើកជាអគ្គមហេសីស្តាំមាននាមហៅថា **សម្តេចព្រះតគទីព្រះឯកក្សត្រីស្រីចក្រពត្តិរតន៍រាជវរលក្ខណ៍** ។ នៅឆ្នាំបន្ទាប់មកទៀត អ្នកម៉ែ **ម៉ែន** (កូនស្រីលោកឧកញ៉ាបវរនាយកសូ) បានប្រសូតបុត្រីនាម **អង្គអី** ។ ចំណែកឯ**អ្នកអង្គអី** បុត្រីព្រះ **កែវហ្វាអង្គជួន** ត្រូវលើកជាអគ្គមហេសីឆ្វេង ហើយមានបុត្រីនាម **អង្គពៅ** ។ ព្រះអគ្គមហេសីឆ្វេងនេះមាននាមហៅថា **សម្តេចព្រះតគវតីព្រះស្រីសុជាតាមហាក្សត្រី** ។

នៅដំណាច់គ.ស.១៧៦៧ ស្តេចភូមានាម **អាឡោងផះយ៉ា** (Alaungpaya) បានលើកទ័ពចូលវាយរាជធានី **អយុធ្យា** ម្តងទៀត ទ្រង់ចាប់យកព្រះចៅ **ឯកទះជឿ** ទៅបាន ។ ឯព្រះរាជបុត្រនាម **ចុលជាស៊ីសាំង** លើកទ័ពចេញច្បាំងចាញ់ភូមា ទ្រង់ភៀសព្រះអង្គចូលនៅក្នុងប្រទេសខ្មែរហើយក្រោយមកសុគតនៅទីនេះ ។

ឆ្លៀតឱកាសដែលស្រុកទេសកំពុងតែកើតចលាចល ចិនម្នាក់ដែលមានម្តាយជាតិជាសៀម និងឪពុកគឺចិន **ហៃហុង** ឈ្មោះ **ពញាតាក** បានកែនទ័ពវាយកំចាត់ភូមាអោយរត់ទៅវិញអស់ ហើយតាំងខ្លួនជាស្តេចក្នុងក្រុង **ស្រីអយុធ្យា** មានព្រះនាមថា ព្រះចៅ **តាកស៊ីន** ។

និយាយពីព្រះអង្គនន់ កាលដែលភូមាវាយបែកក្រុង **អយុធ្យា** នោះទ្រង់បានថយទៅគង់នៅ **បស្ចិមបុរី** រួចត្រឡប់ទៅពឹងព្រះចៅ **តាកស៊ីន** ទៀត ។

នៅគ.ស.១៧៦៨ ព្រះចៅ តាកស៊ីន ទ្រង់បញ្ជារាជទូតអោយនាំសុភអក្សរមកទូលព្រះរាជាខ្មែរអោយទ្រង់លើកសួយជាផ្កាមាស ផ្កាប្រាក់ទៅថ្វាយព្រះអង្គជាផ្លូវព្រះរាជមេត្រី តែព្រះរាជាខ្មែរពុំយល់ព្រមធ្វើតាម ព្រោះព្រះចៅ **តាកស៊ីន** មិនមែនជាក្សត្រ ។ លុះទ្រង់ជ្រាបដំណឹងនេះហើយ ព្រះចៅ **តាកស៊ីន** ទ្រង់ខ្ញាល់ខ្លាំង ទើបទ្រង់ត្រាស់អោយព្រះចៅ **យូហ្សាំងឃ្លា** លើកទ័ពមកដល់នគរវត្តក្នុងបំណងយកព្រះ**អង្គនន់** អោយឡើងសោយរាជ្យនៅប្រទេសខ្មែរ ។ ព្រះរាជាខ្មែរទ្រង់ត្រាស់បញ្ជាក្រឡាហោម **ឃាំង** អោយលើកទ័ពចេញទៅតស៊ូ តែក្រឡាហោម **ឃាំង** ត្រូវស្លាប់ក្នុងសមរភូមិ (36) ។ ត្រង់នេះរាជពង្សាវតារខ្មែរថា ទោះបីមេទ័ពខ្មែរត្រូវបាត់បង់ជីវិតក៏ដោយ ក៏ទ័ពខ្មែរត្រូវបានជ័យជំនះដេញសៀមអោយថយទៅវិញអស់ ។

នៅគ.ស.១៧៦៩ ព្រះរាជាទ្រង់មេត្តា **អ្នកអង្គធម្ម** ជារាជបុត្រព្រះ **កែវហ្វាអង្គជួន** ក៏លើកឡើងជាសម្តេចព្រះមហាឧបរាជ ។

គ្រានោះ ឈ្មោះ **ម៉ាក តោន** (ឯកសារសៀមថាឈ្មោះសម្តេចព្រះសោទ័ត) ជាទេសាភិបាលចិនឈរនៅក្រុង **ពាម** បានកែនទ័ពចេញទៅវាយសៀមដល់ **ចន្ទបុរី** តែត្រូវវាយថយមក **ពាម** វិញអស់ ។

ដើម្បីជាការសងសឹក និងក្នុងបំណងយកប្រទេសខ្មែរជាចំណុះផង ព្រះចៅ **តាកស៊ីន**ទ្រង់បញ្ជាអោយលើកទ័ពមកជា ២ ផ្លូវ ៖ ទ័ពជើងគោកចូលតាមខាងជើងស្ថិតក្រោមបញ្ជាការ ឧកញ៉ាយមរាជ ឯទ័ពជើងទឹកស្ថិតក្រោមបញ្ជាការរបស់ព្រះចៅ **តាកស៊ីន** ហើយដែលមានព្រះ **អង្គនន់** អមផង បានលើកឆ្ពោះមក **ពាម** ។ **ម៉ាក់ ឆោន** បានខិតខំការពារក្រុងណាស់ដែរ តែដោយទន់ដៃជាង ត្រូវទ័ពសៀមដេញតាមរហូតដល់ **ទឹកខ្មៅ** ។

លុះទ្រង់ជ្រាបដំណឹងនេះហើយ ព្រះរាជាខ្មែរទ្រង់នាំរាជវង្សានុវង្សភៀសទៅស្រុកយួន ។ ខ្មែរនិងសៀមច្បាំងគ្នាតទៅទៀត ហើយនៅទីបំផុតសៀមដកថយទៅ **ពាម** វិញអស់ ទុកអោយព្រះ **អង្គនន់** គង់នៅ **កំពត** និងទាហាន ៥០០នាក់ ។ ក្នុងចម្បាំងលើកនេះខាងព្រះ **អង្គតន់** ទំនងជាមានការគាំទ្រពីទ័ពយួន ព្រោះឯកសារយួនបានសរសេរថា "នៅឆ្នាំ ១៧៧២ (?) ខែ ៦ ស្តេច **ង្វៀង** បានបញ្ជាមេទ័ពឈ្មោះ**ង្វៀង គីវ ដាម** (Nguyên Cuu Dam) អោយលើកទ័ពជើងទឹកទៅវាយសៀមនៅភ្នំពេញ ទ័ពសៀមដកថយទៅពាម ចំណែកឯ **អង្គនន់** ទ្រង់ភៀសទៅកំពត " (40) ។

លុះសៀមថយទៅវិញអស់ហើយ ព្រះ **អង្គតន់** យាងត្រឡប់មកសោយរាជ្យវិញ តែទ្រង់ទៅគង់នៅ **ព្រែកមាត់គណ្ឌរ** ។ រាជការយួនក៏បញ្ជូនមន្ត្រីជាន់ខ្ពស់ម្នាក់អោយមកនៅថែរក្សា ចាំជួយសំរេចកិច្ចការផែនដីដែលយួនហៅថា **បាវហោ** (Bao-hô) បានសេចក្តីថាប្រទេសខ្មែរបានធ្លាក់ទៅនៅក្រោមអំណាចគ្រប់គ្រងរបស់យួនម្តងទៀតហើយ ។

នៅគ.ស. ១៧៧២ ព្រះ**អង្គតន់** ទ្រង់យាងទៅគង់នៅ **ព្រែកពាក់ព្រាំត** ។ ព្រះអង្គទ្រង់ព្រះចិន្តាមេត្តាករុណាបណ្តាអាណាប្រជានុរាស្ត្រ ដែលរងទុក្ខវេទនាដោយសារសង្គ្រាមរ៉ាំរៃ ក៏ទ្រង់បញ្ជាអោយព្រះ **កែវហ្វាអង្គជូ** ទៅចរចាចងស្ពានមេត្រីជាមួយព្រះចៅ **តាកស៊ីន** តែព្រះចៅ **តាកស៊ីន**មិនជឿអោយចាប់ឃុំឃាំង ក្រោយមកព្រះ**អង្គជូ** សូមអនុញ្ញាតអោយមាតា ភរិយា និងបុត្រចូលទៅដល់ក្រុង **អយុធ្យា** ទើបព្រះចៅ **តាកស៊ីន** ជឿថាស្មោះត្រង់ពិតក៏អោយលើកលែងទោស ។

នៅគ.ស.១៧៧៣ អ្នកម្នាងរបស់ព្រះ **អង្គតន់** នាម **ទេ** ប្រសូតបុត្រនាម **អង្គអេង** ។ ហើយឆ្នាំក្រោយមកព្រះអង្គយាងទៅគង់នៅ **កោះចិន** ហើយអោយទ័ពយួនថយទៅស្រុកវិញ ។ នៅទីបំផុតព្រះអង្គយាងត្រឡប់ចូលរាជធានី**ឧដុង្គ** វិញ ហើយក្រោយពីពិគ្រោះជាមួយមន្ត្រីធំៗ ហើយទ្រង់សំរេចព្រះទ័យដាក់រាជថ្វាយទៅព្រះ**អង្គនន់**នៅគ.ស.១៧៧៥ ដើម្បីចៀសវាងកុំអោយមានការបង្ហូរឈាមគ្នាឯងតទៅទៀត ។ ចំណែកឯព្រះអង្គទ្រង់ស្ថិតនៅជាមហាឧភយោរាជវិញ ។

## ២. ព្រះរាមរាជា អង្គនន់ (១៧៧៥-១៧៧៩)

ព្រះ**អង្គនន់** ទ្រង់អភិសេកឡើងសោយរាជ្យនៅ **ឧដុង្គមានជ័យ** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្តេចស្តេចព្រះរាមរាជាធិរាជបរមបពិត្រ** ។

លុះទ្រង់ឡើងគ្រប់គ្រងរដ្ឋហើយ ហើយដោយគិតរើបំរះមិនព្រមចំណុះយួនតទៅទៀត នៅគ.ស.១៧៧៦ ព្រះ**រាមរាជា** ទ្រង់បញ្ជាអោយជាងសិតកាំភ្លើងបញ្ចរង្គ កិនរំសេវកាប់ឈើធ្វើបន្ទាយនៅក្រុងភ្នំពេញ និងនៅមុខកំពូល ។

និយាយពីនៅស្រុកយួនឯណោះ មានការបះបោរប្រឆាំង និងស្តេចតាំងពីគ.ស.១៧៧៣ ។ យ៉ាងណាមិញ មានបងប្អូន៣នាក់នៅភូមិ **តី សឺន** (Tây Son) ឈ្មោះ**ង្វៀង ញ៉ាក** (Nguyên Nhac) **ង្វៀង លឺ** (Nguyên Lu) និង **ង្វៀង ហេ** (Nguyên Huê) បានមករួមកម្លាំងជាមួយពួកអ្នកស្រុកភ្នំ លើកទ័ពឆ្ពោះទៅក្រុង **គី ញើន** (Qui Nhon) មូលហេតុនៃការបះបោររបស់ពួក **តី សឺន** នេះ គឺបណ្តាលមកពីរាជនុសិទ្ធឈ្មោះ **ត្រឿង ភុក លន** (Truong Phuc Loan) បានប្រើអំណាចជិះជាន់ប្រជារាស្ត្រខ្លាំងពេក ។ នៅគ.ស.១៧៧៥ ស្តេច **ឌិញ វឿង** (Dinh Vuong) បានភៀសព្រះអង្គទៅនៅស្រុកក្រោម ប៉ុន្តែត្រូវពួកបះបោរចាប់បានហើយធ្វើគុតនៅគ.ស.១៧៧៧ ។ ចំណែកឯក្មួយរបស់ព្រះអង្គនាម **ង្វៀង ភុកអាញ់** (Nguyên Phuc Anh) បានភៀសព្រះអង្គទៅគង់នៅកោះត្រល់ រួចទៅនៅប្រទេសសៀមនៅគ.ស. ១៧៨៤ ។

ក្នុងគ្រានោះ លោកទេសាភិបាលយួនដែលឈរនៅ **ព្រៃនគរ** បានរត់ទៅសុំជំនួយទ័ពពីព្រះ**រាមរាជា** ដើម្បីទៅបង្ក្រាបពួកបះបោរតែព្រះអង្គពុំយល់ព្រម ។ ម៉្លោះហើយ លោកទេសាភិបាលនោះក៏លើកទ័ពយួនចូលមកប្រទេសខ្មែរ ឡើងទៅដល់ក្រុងភ្នំពេញច្បាំងនឹងទ័ពខ្មែរ តែមិនចាញ់មិនឈ្នះ ក៏ដកថយទៅវិញអស់ទៅ ។

នៅគ.ស. ១៧៧៧ លោក **ឧកញ៉ាវិបុលរាជ** នាម **ស៊ូ** ដោយមិនចូលចិត្តនឹងព្រះ **អង្គនន់** បានញុះញង់ព្រះឧបរាជ **អង្គធម្ម** ថា ព្រះ**អង្គនន់** ចង់ប្រទូស្តតែព្រះឧបរាជមិនជឿ ។ ម៉្លោះហើយ ដោយភ័យខ្លាចក្រែងមានទោសកំហុស លោក **ឧកញ៉ាវិបុលរាជ** បានទៅទូលញុះញង់ព្រះ**អង្គនន់** ថាព្រះឧបរាជចង់ក្បត់ដណ្តើមរាជ្យ ព្រះអង្គក៏ព្រមជឿតាមហើយទ្រង់បញ្ជាអោយធ្វើគុតព្រះឧបរាជបានក្នុងពេលលេងចត្រង្គ ដោយមានលោក **ឧកញ៉ាស្រីអគ្គរាជ** ចូលដៃផង ។ ប៉ុន្មានថ្ងៃក្រោយមក ព្រះមហាឧភយោរាជក៏សោយទិវង្គតនៅ **កំពង់ហ្លួង** ទៀតដោយព្រះអង្គព្រួយព្រះទ័យពេក ។

នៅគ.ស.១៧៧៨ ព្រះចៅ **តាកស៊ីន** ទ្រង់បញ្ជាអោយ **ឧកញ៉ាចក្រី** និង **ឧញ៉ាសុរសីហ៍** លើកទ័ព ១០០០០នាក់ទៅវាយលាវនៅ **វៀងចន្ទន៍** ។ ទ័ពនោះបានឆ្លងកាត់តាមស្រុកខ្មែរ លុះទៅដល់**បន្ទាយពេជ្រ** មេទ័ពបានផៀងទៅ **ឧដុង្គ** ទូលព្រះ **រាមរាជា** សូមជួយកងទ័ព និងស្បៀង អាហារ ។

ព្រះ **រាមរាជា** ទ្រង់យល់ព្រមតាម ហើយទ្រង់បញ្ជាអោយកែនទ័ពបានគ្រប់ ១០០០០ នាក់ ប្រគល់អោយមេទ័ពទាំងពីរព្រមទាំងមានស្បៀងជាអង្ករគ្រប់គ្រាន់ទៀតផង ។

ទ័ពខ្មែរលើកទៅជាពីរផ្លូវ ១តាមជើងគោក មួយទៀតតាមជើងទឹក ។ កាលណោះ គេបានកែនពួកស្រីៗ នៅខេត្ត **កំពង់ស្វាយ** អោយបុកអង្ករកិនស្រូវដើម្បីបញ្ជូនទៅអោយកងទ័ព ។ ដំណឹងនេះ ឮទៅដល់ពួកទាហានដែលគេបង្ខំអោយទៅច្បាំងនឹងលាវ ពួកនោះក៏រត់មករកប្រពន្ធកូនវិញ ។ ព្រះ **អង្គនន់** ទ្រង់បញ្ជាអោយរកចាប់បញ្ជូនទៅវិញ ប៉ុន្តែពួកនោះរួមគ្នាប្រឆាំងនឹងព្រះអង្គវិញ រហូតដល់កាប់សម្លាប់ពួកឧកញ៉ាហ្លួងទៀតផង ។

រាជពង្សាវតារបាននិយាយថា ព្រះរាជាទ្រង់បានចោទចៅហ្វាយស្រុកខេត្ត **បារាយណ៍** និងខេត្ត **ព្រៃក្ដី** ដែលត្រូវជាបងប្អូននឹងចៅហ្វាយស្រុកខេត្ត **កំពង់ស្វាយ** ថាឃុបឃិតផ្សំគំនិតនឹងគ្នា ព្រោះ មិនបានថ្វាយដំណឹងខាងលើនោះអោយទាន់ពេលវេលា ។ ម្ល៉ោះហើយ ចៅហ្វាយស្រុកខេត្ត ព្រៃក្ដី **ឧកញ៉ាមន្ត្រីស្នេហាសូរ** ត្រូវកាត់ទោសប្រហារជីវិត ចៅហ្វាយស្រុក **បារាយណ៍ ឧកញ៉ាសៃន្យ ខាងហ្វាពាង** ត្រូវវាយ ៥០រំពាត់ និងត្រូវហូតងារ ឯចៅហ្វាយស្រុក **កំពង់ស្វាយ ឧកញ៉ាតេជោខែន** គ្រាន់តែត្រូវស្តីប្រដៅ ទ្រង់អោយនៅដដែល រួចទ្រង់ប្រោសអោយត្រឡប់ទៅស្រុកវិញ ។

ឆ្នាំបន្ទាប់មក នៅគ.ស.១៧៧៩ មន្ត្រីទាំងពីរជាបងប្អូននឹកតូចចិត្ត និងព្រះរាជាដែលបានកាត់ទោសប្រហារជីវិតប្អូនលោកនោះបានបំបះបំបោររាស្ត្រអោយប្រឆាំងនឹងស្តេច ។ ស្តេចអោយ **ចៅហ្វាមូ** នៅស្រុកបាសាក់លើកទ័ពទៅបង្ក្រាបនៅកំពង់ស្វាយ តែនៅទីបំផុតលោកបានចូលដៃជាមួយប្អូនលោកទាំងពីរប្រឆាំងនឹងស្តេចវិញ ។

ព្រះ**រាមរាជា** ទ្រង់លើកទ័ពទៅបង្ក្រាបផ្ទាល់ព្រះអង្គ ។ នៅពេលនោះ **ឧកញ៉ាវិបុលរាជស៊ូ** ក៏បានចូលដៃជាមួយពួកបះបោរទៀត ។ មន្ត្រីរូបនេះបានទាំងចាប់យកព្រះ **អង្គអេង** ដែលមានព្រះជន្មទើបបាន ៦វស្សា និងអោយធ្វើគុតបុត្រទាំង ៤របស់ព្រះរាជា ។

លុះទ្រង់ជ្រាបដំណឹងនោះ ព្រះរាជាទ្រង់ប្រញាប់លើកទ័ពត្រឡប់មកវិញជួបនឹងទ័ពចំរុះខ្មែរ-យួននៅកំពង់ឆ្នាំង ។ ទាំងសងខាងបានប្រយុទ្ធគ្នាអស់ពេលយ៉ាងយូរតែមិនចាញ់មិនឈ្នះ ។ ព្រះរាជាដកថយទៅនៅជិត **ភ្នំកំរែង** ខេត្ត **ត្រាង** ។

**ចៅហ្វាមូ** ដឹងការណ៍ លើកទ័ពទៅចាប់បានព្រះរាជាយកទៅធ្វើគុតនៅត្រង់ **ចឹងខ្សែង** នៅខាងត្បូងជិតរាជធានី រួចឡើងកាន់អំណាចគ្រប់គ្រងរដ្ឋនៅគ.ស.១៧៧៩ តាំងខ្លួនឡើងឈ្មោះថា **ចៅហ្វាទឡ្ហៈមហារាជបពិត្រ** ។ **ឧកញ៉ាវិបុលរាជស៊ូ** ឡើងជា **ឧកញ៉ាក្រឡាហោម** ។
**ឧកញ៉ាសៃន្យខាងហ្វាពាង** ឡើងជា **ឧកញ៉ាចក្រី** ។ រីឯ**ឧកញ៉ាអធិឥទ្យាប៊ុក** ដែលថែរក្សាព្រះ **អង្គអេង** ឡើងជា **ឧកញ៉ាវាំង** ។

## ខ. ឥទ្ធិពលដ៏ខ្លាំងក្លារបស់សៀម

### ១. ព្រះបាទនារាយណ៍រាជាទី៣ អង្គអេង (១៧៧៩-១៧៩៦)

នៅដំណាច់ឆ្នាំ ១៧៧៩ ពួកមន្ត្រី និងព្រាហ្មណ៍បុរោហិត បានលើករាជសម្បត្តិថ្វាយព្រះ**អង្គអេង** ដែលមានព្រះជន្មទើបបាន ៧ វស្សា ប៉ុន្តែកិច្ចការផែនដីនៅលើកណ្តាប់ដៃ **ចៅហ្វាមូ** ទាំងអស់ ។

ដើម្បីចៀសវាងនូវអំពើក្បត់ផ្សេងៗ **ចៅហ្វាមូ** ចាត់ **ឧកញ៉ាយមរាជបែន** អោយទៅនៅខេត្តកំពង់ស្វាយជាមួយប្អូនលោកគឺ **ឧកញ៉ាតេជោនែន** ។ ចំណែកឯមន្ត្រីធំៗ ឯទៀត ក៏លោកបាន ចាត់វិធានការដូចគ្នានេះដែរ ។

លុះទ្រង់ជ្រាបដំណឹងខាងលើនេះហើយ ព្រះចៅសៀមទ្រង់បញ្ជាព្រះ **អង្គដួង** ដែលត្រូវឃាត់ទុកពីមុននោះ អោយត្រឡប់ចូលប្រទេសខ្មែរធ្វើយ៉ាងណាសុំអោយបាន **ឧកញ៉ាយមរាជបែន** ជាមន្ត្រីចាស់របស់ព្រះបិតាព្រះ**អង្គអេង** ដើម្បីនាំទៅស្រុកសៀម ។ ចៅ **ហ្វាមូ** ក្រោយពីប្រឹក្សានឹង **ឧកញ៉ាក្រឡាហោមស៊ូ** ក៏ព្រមប្រគល់ **ឧកញ៉ាបែន** អោយទៅព្រះចៅសៀម ។ មន្ត្រីរូបនេះត្រូវស្តីបន្ទោសយ៉ាងខ្លាំងពីបទចូលដៃនឹងយួន និងពីឃាតកម្មលើរូបព្រះ **រាមរាជា** ហើយថែមទាំងត្រូវយកទៅដាក់គុកទៀតផង ។

នៅគ.ស. ១៧៨០ ដោយនឹកសង្ស័យថាពួកមន្ត្រីដែលគ្រប់គ្រងរដ្ឋនៅប្រទេសខ្មែរមុខជាចូលដៃនឹងយួនមិនខាន ព្រះចៅសៀមក៏ទ្រង់បញ្ជាអោយលើកទ័ព ២០០០០ នាក់ចូលជា ៣ ផ្លូវ :

- កងទ័ពមួយស្ថិតក្រោមបញ្ជាការរបស់ព្រះរាជបុត្រនាម **ចៅណាយ** លើកឆ្ពោះត្រង់មក **ឧដុង្គ** តែម្តង ។
- កងទី ២ ស្ថិតក្រោមបញ្ជាការរបស់ **ឧកញ៉ាចក្រី** លើកមកបោះជំរំនៅចាំត្រង់តំបន់អង្គរ ។
- កងទី ៣ ស្ថិតក្រោមបញ្ជាការរបស់ **ឧកញ៉ាសុរសីហ៍** លើកចូលលុកយកខេត្តកំពង់ស្វាយ ។

នៅចំពោះមុខការឈ្លានពាននេះ **ចៅហ្វាមូ** បានកែនទ័ព ពង្រឹងបន្ទាយ នាំព្រះ **អង្គអេង** ទៅគង់នៅភ្នំពេញ ហើយចាត់បំរើអោយទៅសុំជំនួយទាហានពីយួន ។ ស្តេច **ង្វៀង ភុក អាញ់** (Nguyên phuc Anh ) បញ្ជាមេទ័ព ២ នាក់គឺ **ង្វៀង ហ៊ីវថ្វាយ** (Nguyên huu Toai) និង **ហូ វ៉ាន់ ឡឹង** (Ho Vân Lân) នាំទ័ព ៣០០០ នាក់មកជួយ (40) ។

ក្នុងពេលដែលសៀម និងយួនកំពុងតែច្បាំងគ្នានៅលើទឹកដីខ្មែរ ព្រះចៅសៀម **តាក ស៊ីន** ទ្រង់កើតវិកលចរិត ។ មេទ័ពសៀមទាំងពីរដែលកំពុងតែធ្វើប្រតិបត្តិការសឹកនៅប្រទេសខ្មែរ ក៏ប្រញាប់ប្រញាល់លើកទ័ពចូលស្រុកវិញ នាំយកទាំងព្រះរាជបុត្រនាម **ចៅណាយ** ទៅជាមួយផង ។ ព្រះចៅ

**តាកស៊ីន** និងព្រះរាជបុត្រត្រូវចាប់ឃុំឃាំងហើយក្រោយមកត្រូវយកទៅធ្វើគុត (គ.ស.១៧៨២) ។ **ឧកញ៉ាចក្រី**ក៏តាំងខ្លួនជាព្រះរាជាមានព្រះនាមថា **សម្តេចព្រះពុទ្ធយ៉តហ្វាចុឡាលោក** ឯ **ឧកញ៉ាសុរសីហ៍** បានតាំងជាឧបរាជ ។

លុះសៀមថយទ័ពទៅអស់ហើយ យួនបានសុំទ័ពខ្មែរអោយជួយវាយពួក **តីសឺន** តែចាញ់ពួកនោះ (ឯកសារយួនគ្មាននិយាយ) ។ ស្តេចយួន **ង្វៀង ភុក អាញ់** រត់ទៅពឹងសៀម (១៧៨៤) ស្តេចសៀមអោយលើកទ័ព ២០ ០០០នាក់ និងសំពៅ ៣០០ មកជួយច្បាំងទៀតតែនៅតែចាញ់ពួក **តីសឺន** ។ នៅទីបំផុត ទ្រង់បានសុំជំនួយពីបារាំងវិញ ។

ក្នុងគ.ស. ១៧៨២ នៅឯប្រទេសខ្មែរឯណោះជម្លោះបានកើតឡើងរវាង **ចៅហ្វាមូ ឧកញ៉ាចក្រីពាង** និង **សម្តេចចៅពញាស៊ូ** ។ **សម្តេចចៅពញាស៊ូ** បានចាត់មនុស្សអោយទៅហៅ **ឧកញ៉ាបែន** មកវិញ ។ នៅគ.ស. ១៧៨៥ **ឧកញ៉ាបែន** បានស្តេចសៀមអនុញ្ញាតអោយត្រឡប់ចូលប្រទេសវិញ ។ **សម្តេចចៅពញាស៊ូ** សុំអោយ **ឧកញ៉ាបែន** បានទៅនៅជាមួយលោក ។ ក្នុងពេលជប់លៀងមួយ បក្សពួករបស់លោកបានសម្លាប់បក្សពួកខាង **ចៅហ្វាមូ**និង **ឧកញ៉ាចក្រីពាង** ។ ឯមន្ត្រីទាំងពីរជាបងប្អូនត្រូវចាប់បានហើយយកទៅប្រហារជីវិតបង់ ។

**សម្តេចចៅពញាស៊ូ**លើកខ្លួនជាធំ គិតកំចាត់ **ឧកញ៉ាបែន** ទៀតតែ **ឧកញ៉ាបែន** ដឹងខ្លួនហើយកំចាត់ **សម្តេចពញាស៊ូ** បានមុន ហើយតាំងខ្លួនជា**សម្តេចចៅហ្វាឡឡៈ** ។ តែទោះបីមាន ជ័យជំនះយ៉ាងនេះហើយក៏ដោយ ក៏បក្សពួក **សម្តេចចៅពញាស៊ូ** បានលើកគ្នាទៅ **ឧដុង្គ** ជាហេតុបណ្តាលអោយ **ចៅហ្វាបែន** ភៀសទៅប្រទេសសៀមនាំទាំងព្រះ **អង្គអេង** និងក្សត្រីទាំង៣អង្គទៅ ជាមួយផង ។

**ចៅហ្វាបែន** ត្រូវបានព្រះចៅសៀមទ្រង់ប្រទានឋានន្តរសក្តិជា **ចៅពញាអភ័យធីបែស ពិសេសសង្គ្រាមរាមនរិន្ទបតី** ។

នៅគ.ស.១៧៩១ អ្នកម្នាង **រូត** មានបុត្រនាមព្រះ **អង្គចន្ទ** ហើយបីឆ្នាំក្រោយមកមានបុត្រ មួយអង្គទៀតនាម **អង្គស្ងួន** ។ អ្នកម្នាងម្នាក់ទៀតមានបុត្រនាម **អង្គអិម** ។ អ្នកម្នាង **ភែ** មានបុត្រនាម **អង្គឌួង** (គ.ស.១៧៩៣) ។

នៅគ.ស. ១៧៩៤ ព្រះ **អង្គអេង** ត្រូវបានព្រះចៅសៀមអភិសេកនៅ **ប៊ាងកក** ដោយមានព្រះនាមហៅថា សម្តេចព្រះ**នារាយណ៍រាជាធិរាជរាមាធិបតី** ។ ឯឧកញ៉ាក្រឡាហោម **ម៉ុក** ដែលបានភៀសទៅជាមួយព្រះ **អង្គអេង** ដែរនោះ ត្រូវបានតាំងជា **ចៅហ្វាឡឡៈ** ជាជំនួស **ចៅហ្វាឡឡៈបែន** ដែលបានតាំងជាស្តេចត្រាញ់ឈរត្រួតខេត្តបាត់ដំបង ។

លុះបានអភិសេកតែងតាំងគ្រប់សព្វហើយ ព្រះចៅសៀមទ្រង់បញ្ជាអោយ **ចៅពញាអត័យធី បែសបែន** លើកទ័ពនាំព្រះ **អង្គអេង** យាងមកសោយរាជ្យនៅប្រទេសខ្មែរ រួចត្រឡប់ទៅឈរត្រួតខេត្ត បាត់ដំបងវិញ តែត្រូវឡើងផ្ទាល់ទៅព្រះចៅសៀម ។ ចំណែកចៅហ្វាយខេត្ត **អង្គរ** ត្រូវស្ថិតនៅក្រោម អំណាចរបស់ **ចៅពញាតំយធីបែសបែន** ។ ដូច្នេះ ចាប់តាំងពីគ.ស. ១៧៩៥មក ខេត្ត **បាត់ដំបង** និងខេត្ត **អង្គរ** ត្រូវបានទៅសៀមដោយសន្តិវិធី ។ ចំពោះការបាត់បង់ទឹកដីនេះ អ្នកប្រវត្តិសាស្ត្រខ្លះបាន ចោទសួរថា តើមានកិច្ចព្រមព្រៀងសម្ងាត់អ្វីមួយរវាងព្រះមហាក្សត្រទាំងពីរដែរឬទេ ? តើនេះជាគុ រង្វាន់ចំពោះស្តេចសៀមដែលបានទទួលស្គាល់ស្តេចខ្មែរ ហើយលើកអោយឡើងសោយរាជ្យ រឺយ៉ាង ណា ? (42) ។ ចំពោះរឿងដដែលនេះ ឯកសារសៀមមួយបានសរសេរថា " ចំណែក **ចៅពញា អត័យធីបែស** (ចៅហ្វាបែន)បានថែរក្សាប្រទេសកម្ពុជារៀបរយល្អ តែជាពួករបស់ព្រះ **រាមរាជា** (អង្គនន់) ក្រែងមិនស្និទ្ធស្នាលជាមួយ **សម្តេចព្រះនារាយណ៍** (អង្គអេង) និង **ចៅហ្វាឡទល្ហៈ** (ចៅហ្វា ប៉ុក) ទើបទ្រង់សុំស្រុក **សៀមរាប** និងស្រុក **បាត់ដំបង** អោយ **ចៅពញាអត័យធីបែស** គ្រប់គ្រងឡើង ដល់ថៃដោយត្រង់ ។ ខេត្តនេះទើបធ្លាក់ទៅក្រោមអំណាចថៃរហូតដល់រជ្ជកាលទី ៥ "(36) ។

រាជពង្សាវតារខ្មែរមួយបានផ្តល់ពត៌មានមានន័យប្រហាក់ប្រហែលនឹងពត៌មានរបស់ឯកសារ សៀមដែរ : ឧកញ៉ា **បែន** គិតថា បើនៅបំរើព្រះ **នារាយណ៍រាជាអង្គអេង** ត្រូវសំពះ**ចៅហ្វា ប៉ុក** ឧកញ៉ា **ឆែន** និង **អង្គជួន** នាំអោយខូចកិត្តិយស គិតថយទៅ **បាត់ដំបង** ឡើងផ្ទាល់ទៅសៀម វិញ ។ ព្រះរាជាក៏ទ្រង់អនុញ្ញាតអោយទៅ ទៅហើយទូលស្តេចសៀមសុំខេត្ត **បាត់ដំបង មហានគរ** ឡើង ផ្ទាល់សៀមជារង្វាន់ ។ ស្តេចសៀមធ្វើសុភអក្សរមកពីរដងទើបព្រះ **អង្គអេង** ព្រមថ្វាយ តែព្រមថ្វាយ សំរាប់តែផែនដីព្រះពុទ្ធយ័តហ្វាមួយទេ (គ.ស.១៧៩៥)(43) ។

នៅគ.ស.១៧៩៦ អ្នកម្នាងរស់បានប្រសូតបុត្រនាម **អង្គជួន** ។ នាឆ្នាំដដែលព្រះ **នារាយណ៍រាជា អង្គអេង** ទ្រង់អាពាធហើយសោយទិវង្គត ។

## ២. ចៅហ្វាប៉ុក (១៧៩៦-១៨០៥)

លុះទ្រង់ជ្រាបពត៌មានខាងលើហើយ ព្រះចៅសៀមទ្រង់បញ្ជាអោយ **ចៅហ្វាប៉ុក** លើកព្រះ **អង្គចន្ទ** ដែលមានព្រះជន្មទើបបាន ៥វស្សាអោយឡើងគ្រងរាជ្យ ហើយអោយលោកទទួលមើលខុស ត្រូវក្នុងកិច្ចការរដ្ឋសិន ។

នៅគ.ស.១៧៩៨ សៀមច្បាំងនឹងភូមា ។ ចៅ **ហ្វាប៉ុក** បានកែនទ័ពទៅជួយច្បាំងឈ្នះភូមា ចាប់ បានឈ្លើយជាច្រើននាំចូលប្រទេសខ្មែរអោយទៅតាំងនៅត្រង់តំបន់ **ប៉ៃលិន** ក្នុងខេត្ត **បាត់ដំបង** ។

នៅគ.ស.១៨០០ ដោយទទួលបញ្ជាពីស្ដេចសៀម **ចៅហ្វ៊ាម៉ុក** បានបញ្ជូនទ័ពទៅជួយ **ង្វៀន គុក អាញ់** ដើម្បីកំចាត់ពួក **តីស៊ឺន** ។ ទាហានណាមិនព្រមច្បាំងត្រូវប្រហារជីវិតបង់ ជាហេតុនាំអោយរាស្ត្រខ្មែរក្ដៅក្រហាយខ្លាំង ។ លុះបានជ័យជំនះលើពួក **តីស៊ឺន** ហើយ **ង្វៀន គុក អាញ់** ឡើងសោយរាជ្យមាននាមថា **យ៉ាឡុង** (Gia-long) ហើយបានផ្ញើសងមកខ្មែរវិញនូវកាំភ្លើងធំ ២ ដើម ដែលយួនបានរឹបយកពីសង្គ្រាមជាមួយព្រះ **អង្គនន់** (ព្រះរាមរាជា) ។

នៅគ.ស. ១៨០៥ ព្រះ **អង្គចន្ទ** ទ្រង់យាងទៅប្រទេសសៀមដោយមាន ចៅ **ហ្វ៊ាម៉ុក** ដង្ហែទៅផង តែលោកបានស្លាប់នៅទីនោះក្នុងជន្មាយុ ៦៥ ឆ្នាំ ។

## គ. យួនមានឥទ្ធិពលខ្លាំងឡើងវិញ

### ១. ព្រះបាទឧទ័យរាជា អង្គចន្ទ (១៨០៦-១៨៣៤)

នៅខែសីហា គ.ស.១៨០៦ ព្រះ**អង្គចន្ទ** ដែលមានព្រះជន្មទើបបាន ១៥ វស្សាបានអភិសេកនៅក្រុង **បឹងកក** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្ដេចព្រះឧទ័យរាជាធិរាជរាមាធិបតីព្រះស្រីសុរិយោពណ៌** ។ រួចហើយព្រះអង្គទ្រង់យាងត្រឡប់មកសោយរាជ្យនៅក្រុង **ឧដុង្គ**វិញ ។ បីខែក្រោយមក **ចៅពញាអភ័យធីបែសបែន** បានយកកូនស្រីឈ្មោះ **ទេព** មកថ្វាយជា ម្នាង ។

បន្ទាប់មក **ព្រះឧទ័យរាជា** ទ្រង់អោយនាំគ្រឿងបណ្ណាការទៅថ្វាយស្ដេចសៀម សុំយាងក្សត្រាក្សត្រីខ្លះមកវិញ ។ ស្ដេចសៀមអោយតែព្រះមាតា និងរាជបុត្រី **អង្គពៅ**ត្រឡប់មកវិញ (១៨០៧) ។

នៅគ.ស.១៨០៩ អ្នកម្នាង **ទេព** ប្រសូតបុត្រីនាម **អង្គប៉ែន** ។ នៅឆ្នាំដដែលព្រះចៅសៀមសោយទិវង្គត ហើយព្រះរាជបុត្រច្បងឡើងសោយរាជ្យស្នង ។ ឯ **ចៅពញាអភ័យធីបែសបែន** ក៏ទទួលមរណភាពដំណាលគ្នានោះដែរ ។ កូនលោកគឺ **ឧកញ៉ាវិបុលរាជបែន** ត្រូវបានព្រះចៅសៀម តែងតាំងអោយកាន់តំណែងជាជំនួសឪពុកលោក ។

**ព្រះអង្គចន្ទ** ទ្រង់បានចាត់អោយព្រះអនុជនិងមន្ត្រីខ្លះទៅចូលរួមក្នុងពិធីបុណ្យសពស្ដេចសៀម ។ ព្រះចៅសៀមដែលសោយរាជ្យស្នងបិតាទ្រង់សព្វព្រះទ័យតាំងព្រះ **អង្គស្ងួន** ជាឧភយោរាជ និងតាំងព្រះ**អង្គអិម** ជាឧបរាជ ។

ក្រោយមក វិវាទបានកើតឡើងរវាងព្រះ**អង្គចន្ទ**និងព្រះអនុជជាឧភយោរាជ ។ បុព្វហេតុទំនងជាបណ្ដាលមកពីស្ដេចសៀមពុំបានសួរយោបល់ពីព្រះអង្គក្នុងការតែងតាំងនេះ ។ ព្រះឧភយោរាជ និងគ្រួសារទ្រង់បានភៀសទៅនៅពោធិ៍សាត់ ។ ព្រះរាជាទ្រង់បានសូមសម្ដេចព្រះសង្ឃរាជ និងចាត់មន្ត្រី

អោយសូមយាងមកវិញតែឥតប្រយោជន៍ ។ ដោយហេតុខ្លាចក្រែងមានចម្បាំងគ្នាឯងក្នុងស្រុកកើតឡើង ព្រះអង្គក៏ទ្រង់ចាត់អោយទៅសុំទ័ពយួនមកបង្ការ ។ ទ័ពនេះបានមកហើយទៅបោះនៅត្រង់**កោះចិន** ។

ប្រហែលជាចាប់ពីពេលនោះ ព្រះអង្គទ្រង់បានខិតជិតមកខាងយួន ទ្រង់ទុកដាក់ប្រទេសខ្មែរជាសាមន្តរដ្ឋ ហើយលើកសួយសារអាករទៅថ្វាយស្តេច **យ៉ាឡុង** ៣ឆ្នាំម្តង ។

ចំណែកព្រះចៅសៀមទ្រង់មិនពេញព្រះទ័យចំពោះអំពើរបស់ព្រះ**អង្គចន្ទ** ដែលបានងាកទៅរកយួនជាមិត្តនោះវិញ ។ ម្ល៉ោះហើយ ក៏ទ្រង់បញ្ជូនទ័ពអោយចូលប្រទេសខ្មែរជា៣ផ្លូវ ។

ទ័ពចំរុះ ខ្មែរ-យួន ច្បាំង និងទ័ពសៀម ។ ដោយឃើញស្ថានការណ៍មានសភាពកាន់តែធ្ងន់ ព្រះ**អង្គចន្ទ** និងព្រះអនុជទាំងពីរគឺ **អង្គអិម** និង **អង្គដួង** ដកថយទៅគង់នៅ **តិចចូវ** (Tân Châu) ។ នៅពេលយប់ ព្រះឧបរាជ **អង្គអិម** និង **អង្គដួង** នាំព្រះមាតា និងបណ្តាខ្ញុំរត់ទៅប្រទេសសៀមជាមួយ **អង្គស្ងួន** ។

នៅគ.ស.១៨១៣ ក្រោយពីបានធ្វើការសំរុះសំរួលជាមួយសៀមខ្លះហើយ ស្តេច **យ៉ាឡុង** ទ្រង់បានបញ្ជាអោយលោក **ឡេ វ៉ាន់ យៀត** (Lê Van Duyêt) ហែរព្រះ**អង្គចន្ទ** អោយត្រឡប់មកសោយរាជ្យនៅប្រទេសខ្មែរវិញ ។ ពេលទ័ពយួនមកដល់ ពួកមេទ័ពសៀមបែរជាស្រឡាំងកាំង ដកទ័ពថយទៅវិញ ហើយមានមេទ័ពខ្លះមកថ្វាយស័ព្ទសាធុកាពរចំពោះព្រះអង្គថែមទៀតផង ។

ឯកសារសៀមក្តី (36) រាជពង្សាវតារខ្មែរក្តី បាននិយាយស្របគ្នាថា ទោះបីព្រះអង្គស្ថិតស្ថាលនឹងយួនជាងក៏ដោយ ក៏ព្រះ **អង្គចន្ទ** បាននាំគ្រឿងបណ្ណាការទៅថ្វាយស្តេចសៀមក្នុងឋានៈជាប្រទេសរាជ ។

នៅគ.ស. ១៨១៤ សៀមលើកទ័ពចូលម្តងទៀត តែពុំមែនមកកំចាត់យួនដូចពេលមុនៗទេ គឺមកដណ្តើមយកទិកដីខ្មែរដោយត្រង់ៗតែម្តង : ដូច្នោះទិកដីខ្មែរ៣ខែត្រទៀតត្រូវបានទៅសៀមចាប់តាំងពីពេលនោះទៅគឺ **មូលព្រៃ ទន្លេរពៅ** និង**ស្ទឹងត្រែង (សូមមើលផែនទី)** ។ បើតាមលោក Moura (42) ការបាត់បង់ទិកដីខាងលើនេះ គឺបណ្តាលមកពីចៅហ្វាយស្រុកខេត្ត **កំពង់ស្វាយ** ឈ្មោះ **ម៉ឹង** បានទៅអះអាងប្រាប់ព្រះចៅសៀមថា ប្រជារាស្ត្រក្នុងខេត្តទាំងប៉ុន្មាននោះ បានសុំដោយទទូចអោយខ្លួនបាននៅក្រោមអំណាចគ្រប់គ្រងរបស់សៀម ។

ឯកសារយួនមួយបានសរសេរថា លោក **ឡេ វ៉ាន់ យៀត** ទេសាភិបាលនៅ **យ៉ាឌិញ** បានទទួលសូមអនុញ្ញាតពីស្តេចយួនអោយសង់បន្ទាយនៅភ្នំពេញ និងនៅ**ល្វាឡែម** (ល្វាឯម) ។ លុះបន្ទាយទាំងនោះសង់រួចស្រេចហើយ ស្តេចយួន **ថេតោ** (Thê tô) គឺស្តេច **យ៉ាឡុង** បានបញ្ជាអោយមេទ័ព **ង្វៀង វ៉ាន់ធុយ** (Nguyên-vân-thuy) យកទាហាន ១០០០នាក់ទៅតាំងអាណាព្យាបាលភាពលើប្រទេស **ចឹនឡាប** (ប្រទេសខ្មែរ) (40) ។

ចំណែកឯទេសាភិបាលយួនឈរនៅកម្ពុជាក្រោម មានអំណាចសំរេចរាជការគ្រប់បែបយ៉ាងលើប្រទេសខ្មែរ គឺទាំងខាងរដ្ឋបាល និងទាំងខាងយោធា (42) ។

រាជពង្សាវតារខ្មែរបានបញ្ជាក់បន្ថែមទៀតថា **អុង តា គុន** (គឺ **ឡេវ៉ាន់យៀត**) បានសាងវាំងថ្មីមួយនៅខាងត្បូង **វត្តឧណ្ណាលោម** ហៅថា **ព្រះរាជវាំងតំរៃងតែង** ហើយយាងព្រះ**ឧទ័យរាជា** អោយមកគង់នៅក្នុងវាំងថ្មីនេះ ។ ម្យ៉ាងទៀត លោកបានអោយលើកដីសង់ **ជំណាក់ព្រះធារមី** មួយនៅជ្រោយចង្វារ តែដល់ថ្ងៃ ១កើត និង១៥កើតអោយអស់មន្ត្រីយួនខ្មែរទៅសំពះរំលឹកគុណស្តេចយួន ។ ពេលទៅនោះ ទាំង **ព្រះឧទ័យរាជា** ទាំងនាម៉ឺនសព្វមុខមន្ត្រីសុទ្ធតែស្លៀកខោពាក់អាវជួតឈ្នួតក្បាលតាមបែបយួនទាំងអស់ ។

នៅគ.ស.១៨១៥ អ្នកម្នាង**ក្រចាប់** មានបុត្រីនាម **អង្គម៉ី** ។

នៅឆ្នាំដដែល ស្តេចយួនទ្រង់ចាត់អោយសង់បន្ទាយនៅ **មាត់ជ្រូក** និងជីកព្រែកពីរនៅក្នុងទឹកដីយួន :

- ព្រែកមួយ ហៅថា ព្រែក **វិញតេ** (Vinh-tê) មានប្រវែង ៥៣គ.ម. ត្រូវតភ្ជាប់មាត់ជ្រូកទៅនិងសមុទ្រនៅតំបន់ពាម ។

- ព្រែកមួយទៀត ហៅថា **វិញអាន** (Vinh-an) មានប្រវែង ១៤គ.ម. ទទឹង២៤ម. ត្រូវតភ្ជាប់ទន្លេធំទៅនឹងទន្លេបាសាក់ ។

រាជពង្សាវតារខ្មែរបានបញ្ជាក់ថា ក្នុងការជីកព្រែកទាំងពីរខាងលើនេះ ប្រជារាស្ត្រខ្មែរត្រូវគេកែនទៅ ហើយត្រូវយួនធ្វើបាបគ្មានត្រាប្រណីដល់តិចតួចសោះឡើយ ។ រឿង**កំពប់តែអុង** ដែលយួនវាយកខ្មែរកប់ទាំងរស់យកក្បាលធ្វើជើងក្រានដាំតែ បានកើតឡើងនៅសម័យនោះឯង ។ ឯកសារខ្មែរមួយទៀតបានសរសេរទាក់ទងនឹងរឿងនេះដែរថា ក្តីលំបាកវេទនារបស់ខ្មែរ ជាគូលីកំណែននេះប្រៀបបាននឹងឋាននរក ។ មួយថ្ងៃៗ ធ្វើការតាំងពីព្រលឹមទល់ព្រលប់ ឥតមានសំរាក់ឡើយ ទឹកសំរាប់ផឹកមានក្លិនលាមក បាយស៊ីទៅហើមពោះ បណ្តាលអោយកើតរោគ យួនវាយសំពងថែមទៀត ដោយចោទថាខ្មែរខ្ជិល ខ្មែរធ្វើពុត ខ្មែរយឺត ។នៅពេលដែលយួនបើកទឹកបង្ហូរចូលព្រែកយួនឥតប្រាប់ខ្មែរទេ បណ្តាលអោយកម្មករកំណែនខ្មែរដែលរត់មិនទាន់លិចលង់ក្នុងព្រែកស្លាប់ជាច្រើន ។ ចំពោះអំពើព្រៃផ្សៃអមនុស្សធម៌របស់យួន ព្រះ **អង្គចន្ទ** ឥតបានតវ៉ាអ្វីឡើយ មានតែមន្ត្រីម្នាក់បានចេញមុខការពារ ។ យួនដឹងក៏ចាប់មន្ត្រីនោះទៅសំលាប់ចោល ។ ក្រៅពីកែនខ្មែរអោយទៅជីកព្រែក យួននៅ បានបង្ខំខ្មែរអោយកាប់ព្រៃឈើអោយគេថែមទៀត ។ ដំបូងគេប្រើគោ ក្របី រទេះសំរាប់អូសឈើ តែដល់សត្វស្លាប់អស់ទៅដោយកាប់ឈើច្រើនពេក គេក៏ប្រើមនុស្សអោយអូសវិញ ។ អំពើអមនុស្សធម៌នេះបណ្តាល

អោយប្រជារាស្ត្រខ្មែរ ព្រះសង្ឃខ្មែរទ្រាំពុំបាន ក៏នាំគ្នាកាប់សំលាប់យួនអស់ជាច្រើន ។ តែយួនសងសឹកខ្មែរវិញយ៉ាងសាហាវជាទីបំផុត(18) ។

នៅគ.ស.១៨២០ មានភិក្ខុ១អង្គនាម**កែគង់** បួសនៅវត្តសំបួរក្នុងខេត្តភ្នំពេញបានតាំងខ្លួនជាអ្នកសិល្ប៍ភូវិសេស ទៅបញ្ចុះបញ្ចូលអស់រាស្ត្រនៅខេត្ត **បាភ្នំ** រួចទៅរួបរួមនឹង **សម្តេចចៅពញាតី ឧកញ៉ានរេន្ទគល់** និងនាយ **កែព្រាល** លើកទ័ពទៅកាប់សម្លាប់យួនអស់ជាច្រើន ។ ពេលនោះ **អុងតាគុន ឡេ វ៉ាន់ យៀត** នៅព្រៃនគរ ប្រើអោយនាំពល៣០០នាក់លើកដល់ភ្នំពេញហើយ បង្ហូសទៅបោះនៅ **កោះសូតិន** ទើបសម្តេច ព្រះ **ឧទ័យរាជា** ទ្រង់បញ្ជាអោយលើកទ័ពទៅជាបន្ថែម ហើយចាប់បានភិក្ខុ **កែគង់** យកទៅសម្លាប់ ។ ចំណែកឯ **សម្តេចចៅពញាតី ឧកញ៉ានរេន្ទគល់** នាយ **កែព្រាល** ត្រូវចាប់បានបញ្ជូនទៅ**ព្រៃនគរ** ហើយក្រោយមកត្រូវប្រហារជីវិតបង់ដែរ ។ រាជពង្សាវតារបានបញ្ជាក់ថា ឧប្បត្តិហេតុនេះកើតមកពីការវិវាទរវាងនាម៉ឺនខ្មែរ និងនាម៉ឺនយួន ។

នៅគ.ស. ១៨២១ ម្នាងម្នាក់នៃ **អង្គជួង** បានប្រសូតបុត្រីនាម **ម៉ុំ** ។ នៅឆ្នាំក្រោយអ្នកម្នាង **យស** របស់ព្រះ**អង្គចន្ទ** មានបុត្រីនាម **អង្គពៅ** ។

នៅគ.ស.១៨២៩ អ្នកម្នាង**ម៉ែន** (ប្អូនអ្នកម្នាងក្រចាប់)មានបុត្រីនាម **អង្គស្ងួន** ។

នៅគ.ស. ១៨៣២ សៀមលើកទ័ពមកតាមផ្លូវបាត់ដំបង ពោធិ៍សាត់ ហើយមករហូតដល់កំពង់ឆ្នាំង ។ ទ័ពខ្មែរស្ថិតនៅក្រោមបញ្ជាការរបស់ចក្រី **ឡុង** បានប្រយុទ្ធជាមួយទ័ពសៀមនៅ **ចឹងពោធិ** តែនៅទីបំផុតខ្មែរទន់ដៃជាង បាក់ទ័ព ហើយចក្រី **ឡុង** ក៏ភៀសទៅនៅខេត្តបាភ្នំ ។ បរាជ័យរបស់ខ្មែរលើកនេះជាហេតុបណ្តាលអោយព្រះ **ឧទ័យរាជា** ភៀសទៅស្រុកក្រោមម្តងទៀត ហើយទៅគង់នៅ **លង់ហោរ** ។ ទ័ពសៀមដែលមាន **ពញាបឌិនតេជោ** ជាមេបញ្ជាការបាននាំព្រះ**អង្គអិម** មហាឧបរាជនិងព្រះ**អង្គដួង** មកទុកអោយគង់នៅភ្នំពេញ ហើយលើកបង្ហូសទៅប្រយុទ្ធជាមួយយួននៅ **មាត់ជ្រូក** វាយឈ្នះយកបានបន្ទាយនេះ ។

នៅពេលនោះ ឧកញ៉ាចក្រី **ឡុង** ដែលបានភៀសទៅបាភ្នំនោះ បានទៅកែនទ័ព ហើយវាយឈ្នះទ័ពសៀមដែលឆ្លងទៅត្រើយខាងកើត ។

ចំណែកឯ **ពញាបឌិនតេជោ** ដែលវាយឈ្នះយួននៅមាត់ជ្រូកនោះបានជម្រុលទៅដល់ **លង់ហោរ** តែត្រូវទទួលបរាជ័យក្នុងចម្បាំងជើងទឹកជាមួយយួន ។

សៀមលើកទ័ពថយទៅវិញអស់ ។ លុះទ្រង់ជ្រាបដំណឹងនេះ ព្រះ **អង្គអិម** និងព្រះ **អង្គដួង** ក៏យាងភៀសទាំងពីរអង្គទៅខេត្តបាត់ដំបង ។

លុះសៀមដកទ័ពថយទៅវិញអស់ហើយ យួននាំព្រះ **ឧទ័យរាជា** ត្រឡប់មកសោយរាជ្យនៅភ្នំពេញវិញ ។ ចក្រី **ឡុង** ត្រូវបានតាំងជា **ចៅហ្វ៊ានឡុះ** ។

យួនបានសង់ **បន្ទាយអាណ្ណាម** នៅជិតក្រុងភ្នំពេញ ហើយចាត់មេទ័ពឈ្មោះ **ត្រឿង មិញ យ៉ាង** (Truong minh Giang) និងមន្ត្រីឈ្មោះ **ឡេ ដាយ គឿង** (Lê dai-Cuong) អោយ ឈរត្រួតប្រទេសខ្មែរ ។

ព្រះ**ឧទ័យរាជា** ទ្រង់សោយទិវង្គតនៅគ.ស.១៨៣៤ ដោយរោគរាគក្នុងព្រះជន្ម ៤៤ព្រះវស្សា ។

## ២. ក្សត្រីអង្គម៉ី (គ.ស.១៨៣៤-១៨៤០)

ព្រះចៅ **មិញម៉ាង** (Minh Mang) ដែលជារាជបុត្រសោយរាជ្យស្នងព្រះចៅ **យ៉ាឡុង** ទ្រង់បញ្ជូន **អុង ខាំ ម៉ាង** អោយនាំគ្រឿងបណ្ណាការឡើងមកជួយការបុណ្យព្រះបរមសព ។ រាជទូតរូបនេះ នៅមានបេសកកម្មម្យ៉ាងទៀតគឺការជ្រើសរើសក្សត្រអោយឡើងសោយរាជសម្បត្តិស្នងព្រះ**ឧទ័យរាជាអង្គចន្ទ** ។ តាមពិតលោកបានទទួលបញ្ជាជាស្រេចពីព្រះចៅ **មិញ ម៉ាង**ថាត្រូវជ្រើសរើសក្សត្រអង្គណាអោយឡើងកាន់អំណាចហើយ ដូចមានសេចក្តីបញ្ជាក់ពីព្រះរាជពង្សាវតារថា **អុង ខាំ ម៉ាង** បាននាំទាំងព្រះនាមមកថ្វាយរៀបអភិសេកអ្នក **អង្គម៉ី** ជាព្រះរាជបុត្រីបន្ទាប់អោយគ្រប់គ្រងក្រុងកម្ពុជាធិបតី ។ ប៉ុន្តែ ដើម្បីជាការបិទបាំងកុំអោយអ្នកផងស្គាល់ព្រះរាជបំណងព្រះចៅយួន លោកបានធ្វើការប្រឹក្សាសួរយោបល់នៃមន្ត្រីខ្មែរ ដោយបានបញ្ជាក់ថា ត្រូវចៀសវាងកុំលើកក្សត្រទាំងឡាយដែលបានភៀសទៅខាងសៀមមានព្រះ **អង្គអិម** មហាឧបរាជ និងព្រះ **អង្គដួង** ជាដើម និងត្រូវចៀសវាងកុំលើកក្សត្រី **អង្គប៉ែន** ព្រោះព្រះមាតាជាអ្នកស្និទ្ធស្នាលនឹងសៀមទៀត (42) ។

ដោយហេតុនោះ ក្សត្រី**អង្គម៉ី** ជាបុត្រីបន្ទាប់នៃព្រះ **ឧទ័យរាជាអង្គចន្ទ** ត្រូវលើកអោយឡើងសោយរាជ្យ ក្នុងព្រះជន្ម២០វស្សា នៅ **កោះស្លាកែត** ដោយមានព្រះនាមហៅតាមយួនថា **បា កុង ចៅ** (bâ cong chua) ប៉ុន្តែបើតាមឯកសារយួនថា មានព្រះនាមថា **ង៉ុក វឺង កុង ជ័ួ** (Ngoc Vân công Chua) ហើយមានព្រះឋានៈត្រឹមតែជា **ក្វឹង ជ័ួ** (quân chua) គឺស្មើនឹងចៅហ្វាយខេត្តម្នាក់ប៉ុណ្ណោះ ។ ចំណែកឯក្សត្រី **អង្គពៅ** ត្រូវលើកជាឧបរាជិនី និងក្សត្រី **អង្គស្ងួន** ត្រូវលើកជា **កែវ ហ្វា** (40-44) ។

ចំពោះការជ្រើសរើសក្សត្រីមួយអង្គអោយឡើងគ្រងរាជ្យនេះ លោក Adhémard Leclère បានសរសេរថា : "ការជ្រើសរើសតាំងនេះពុំបានធ្វើអោយអាណាប្រជារាស្ត្រងឿងឆ្ងល់ពេកទេ ព្រោះថាបើគេពុំដែលនឹកឃើញថាស្ត្រីម្នាក់អាចត្រូវបានលើកអោយឡើងសោយរាជ្យនៅប្រទេសកម្ពុជា ក៏គេធ្លាប់បានឃើញជាញយដងដែរថា មានព្រះរាជាខ្លះដោយជក់ព្រះទ័យខ្លាំងនឹងការសាងផ្នួស ទ្រង់បានប្រគល់អំណាចទៅអោយព្រះអគ្គមហេសី ឬព្រះមាតាដែរ " (44) ។



ប្រទេសចិន
ហាណូយ
រាជាណាចក្រ
ហ្លួងព្រះបាង
រាជាណាចក្រវៀងចន្ទ
វេ
រាជាណាចក្រ
ចម្ប៉ាស័ក
ប្រទេសសៀម
ទន្លេរពៅ
ស្ទឹងត្រែង
មូលព្រៃ
សៀមរាប
បាត់ដំបង
ត្រាំង
ចាញ់
យួន និងសៀម
ចែកទឹកដីខ្មែរ
នៅស.វ.ទី ១៩
មាត្រដ្ឋាន 1/7500000

ឯកសារផ្សេងៗបានបញ្ជាក់អោយឃើញថា ក្នុងរជ្ជកាលរបស់ព្រះអង្គក្សត្រី **អន្គម៉ី** ពុំមានអំណាចអ្វីធំដុំឡើយ ហើយយួនបានចាត់វិធានការគ្រប់បែបយ៉ាងដើម្បីអោយខ្មែរក្លាយទៅជាយួន ជាហេតុបណ្តាលអោយអាណាប្រជានុរាស្ត្របានដល់នូវសេចក្តីទុក្ខវេទនាឥតស្រាកស្រាន្ត ។

ជាដំបូង ប្រទេសខ្មែរត្រូវគេផ្លាស់អោយមានឈ្មោះហៅថា **ត្រឹន តី ថាញ់** (Trân tay-thành) (១) ហើយត្រូវចែកជា ៣២ **ភូ** (phu) (២) និង ២ **ហ្វៀន** (huyên) (៣) ។ នៅប្រទេសខ្មែរទាំងមូលមានមេទ័ពម្នាក់ និងមន្ត្រីយួនជាច្រើននាក់ទៀតជាអ្នកមើលការខុសត្រូវក្នុងកិច្ចការរដ្ឋទាំងឡាយ ។ នៅកន្លែងណាដែលជាចំណុចយុទ្ធសាស្ត្រនោះ មានចាត់អោយមានជាបន្ថែមនូវមន្ត្រីដែលយួនហៅថា **ទៀន ភូ** (tuyên phu) និង **អាន ភូ** (an-phu) (៤) ដើម្បីការពារថែមទៀត (40) ។

ឈ្មោះខ្មែរទាំងឡាយ គិតតាំងពីឈ្មោះមនុស្សរហូតដល់ឈ្មោះក្រុង ខេត្ត ស្រុក ភូមិ សុទ្ធតែត្រូវផ្លាស់ប្តូរអោយមានសូរសៀងជាយួនទាំងអស់ (44-46) :

- **ក្សត្រីអន្គម៉ី** . . . **ង៉ុក វ៉ាន កុង ជួ** (Ngoc Vàn công -chua)
- **ចៅហ៊្វាឡុង** . . . **ត្រា ឡុង** (Tra Long)
- **ភ្នំពេញ** . . . **ណាម វ៉ាង** (Nam Vang)
- **បន្ទាយពេជ្រ** . . . **កប៊ិច** (Co Bich)
- **លង្វែក** . . . **ឡាឡែម** (La Lêm)
- **ឧដុង្គ** . . . **បាក់ កូ ណាម** (Bac Co Nam)
- **សំរោងទង** . . . **ឡុង តោន** (Long tôn)
- **បន្ទាយមាស** . . . **សាយ ម៉ាត** (Sai mat)
- **កំពត** . . . **កឹន វ៉ត** (Cân vot)

---

(១). **ត្រឹន** (trân) = មណ្ឌលរដ្ឋបាលមួយក្នុងសម័យបុរាណរបស់យួន

**តី** (tây) = ខាងលិច

**ថាញ់** (thành) = បន្ទាយ

ដូច្នេះ **ត្រឹន តី ថាញ់** មានន័យថា មណ្ឌលរដ្ឋបាលមួយជាបន្ទាយនៅទិសខាងលិច ។

(២). **ភូ** ស្មើនិងខេត្តមួយ

(៣). **ហ្វៀន** ស្មើនឹងស្រុកមួយ

(៤). សក្តិស្មើចៅហ្វាយខេត្ត ?

- **បាសាក់** . . **បាថាក់** (Ba thac)

- **ព្រះត្រពាំង** . . **ត្រាវិញ** (Travinh)

- **ពាមបន្ទាយមាស** . . **ហាទៀន** (Hatiên)

- **ស្រុកឃ្លាំង** . . **សុក ត្រាំង** (Soctrang) ។ ល ។

រាជពង្សាវតារខ្មែរបានបញ្ជាក់ថា កាលណោះ **អុង តា គុន** ជាធំនៅថែរក្សាស្រុកភ្នំពេញ បានធ្វើអោយនាម៉ឺនសព្វមុខមន្ត្រីខ្មែរមានការក្តៅក្រហាយ ដោយបង្ខំអោយស្លៀកពាក់ខោអាវ អោយជួតក្បាល និងអោយមានងារសក្តិហៅតាមបែបយួនទាំងអស់ ។ ម្យ៉ាងទៀត ចៅហ្វាយស្រុកនៃខេត្តខ្មែរទាំងអស់សុទ្ធតែមានមន្ត្រីយួននៅអមដើម្បីចាំត្រួតពិនិត្យ និងឃ្លាំមើលសកម្មភាពជាអចិន្ត្រៃយ៍ ។

អាណាប្រជានុរាស្ត្រត្រូវបង្ខំអោយបង់ពន្ធជាទម្ងន់ ត្រូវកែនចាប់ប្រើអោយធ្វើស្រែកាប់ចំការខ្លះ បំពេញកិច្ចការសាធារណៈខ្លះដូចជាសង់បន្ទាយ លើកផ្លូវពីភ្នំពេញទៅខេត្តទ្រាំងបន្ទាយមាស ។ នៅតាមបណ្តោយផ្លូវនោះតម្រូវអោយសង់រោងមានមនុស្សប្រចាំការ ៣ នាក់គ្រប់ដំណាក់ដែលយួនហៅថា **ត្រាម** (Tram) ។

ចំណែកឯព្រះពុទ្ធសាសនា ក៏ត្រូវរាជការយួនធ្វើទុក្ខបុកម្នេញយ៉ាងខ្លាំង ។ វត្តអារាមត្រូវរុះរើ ព្រះពុទ្ធរូបត្រូវវាយកំទេច ។ នៅឯស្រុកក្រោម ស្តេច **មិញ ម៉ាង** បានបង្ខំអោយព្រះសង្ឃខ្មែរប្រព្រឹត្តដូចលោកសង្ឃយួនផ្នែកមហាយាន គឺត្រូវកោរសក់ទុកចិញ្ចើម មិនឆាន់សាច់ ស្លៀកខោពាក់អាវជាយកត្រង់ពណ៌ឈាមជ្រូក ពេលសូត្រធម៌ត្រូវមានវាយត្រដោកផង (45-47) ។ គឺនៅក្នុងក្របខ័ណ្ឌប្រឆាំងនឹងការបំបាត់ទំនៀមទំលាប់ប្រពៃណីខ្មែរនេះហើយ ដែលលោកចៅហ្វាយស្រុកខេត្តព្រះត្រពាំងនាមចៅហ្វាយ **គុយ** សុខចិត្តធ្វើពលីកម្មបូជាជីវិតដើម្បីថែរក្សាកេរមត៌កពីដូនតាតទៅទៀត ។

នៅឯកម្ពុជាលើ ក៏មានមន្ត្រីជាច្រើនបានប្រឆាំងចំពោះការជិះជាន់របស់យួន ខ្លះក៏ត្រូវចាប់បានហើយយកទៅប្រហារជីវិត ខ្លះទៀតក៏រត់រួចចូលទៅខាងសៀម ។

នៅគ. ស. ១៨៤០ ស្តេច **មិញ ម៉ាង** ទ្រង់បញ្ជាមន្ត្រីជាន់ខ្ពស់ពីរនាក់ទៀត គឺ **ឡេ វ៉ាន់ ឌឹក** (Lê văn Duc) និង **យន អ៊ុន** (Doan Uân) អោយមកជួយ **ទ្រឿង មិញ យ៉ាង** ក្នុងការគ្រប់គ្រងប្រទេសខ្មែរ ជាពិសេសក្នុងការត្រួតពិនិត្យពាណិជ្ជកម្ម ការកំរិតពន្ធដា និងការវាស់វែងដីស្រែ (40) ។

នៅឆ្នាំដដែលនោះ ដើម្បីចៀសវាងនូវការបះបោរដែលអាចកើតមានឡើង **ទ្រឿង មិញ យ៉ាង** បានប្រើឧបាយបញ្ជាអោយមន្ត្រីជំនិតនាំសារទៅថ្វាយព្រះ**អង្គឌួង** មហាឧបរាជ ដែលព្រះចៅសៀមនាម **ណាំង ក្លាវ** ទ្រង់ប្រោសអោយទៅគង់នៅបាត់ដំបង ថាសូមយាងព្រះអង្គចូលសោយរាជ្យ នៅប្រទេសកម្ពុជា ។ លុះឮដូច្នោះហើយ ព្រះមហាឧបរាជក៏ជឿតាមទ្រង់បញ្ជាអោយមន្ត្រីទូលបង្គាច់ថាព្រះអនុជ

**អង្គដួង** ចង់រត់ចូលក្រុងកម្ពុជាដើម្បីឡើងសោយរាជ្យ ។ ពេលនោះ ព្រះចៅសៀមទ្រង់បានបញ្ជាអោយគេនាំព្រះ **អង្គដួង** ត្រឡប់ចូលក្រុង **ចឹងកក** វិញ ។

ចំណែកឯព្រះមហាឧបរាជទ្រង់បានធ្វើដំណើរមកដល់ភ្នំពេញ ។ **ទ្រឿង មិញយ៉ាង** បានបញ្ជាអោយនាំបង្គួសយកទៅដល់ក្រុង **វេ** ។

បន្ទាប់ពីនោះ **ទ្រឿង មិញយ៉ាង** បានប្រើកលម្តងទៀតថា សូមអញ្ជើញមន្ត្រីជាន់ខ្ពស់របស់ខ្មែរមាន **ចៅ ហ្វ៊ា ឡុង** ជាដើមអោយទៅក្រុង **វេ** ថាដើម្បីពិភាក្សាពីកិច្ចការរដ្ឋជាមួយព្រះចៅយួន និងព្រះមហាឧបរាជ ។

លុះពួកមន្ត្រីចេញដំណើរទៅអស់ហើយ **ទ្រឿង មិញយ៉ាង** បានបញ្ជាអោយគេចាប់ក្សត្រីទាំង ៤ បញ្ជូនទៅស្រុកក្រោមទៀត ។ លុះទៅដល់ **លង់ហោរ** លោកចៅហ្វាយខេត្តនេះអោយតែក្សត្រី ៣ អង្គ គឺ **អង្គមី អង្គពៅ** និង**អង្គស្ងួន** បន្តដំណើរទៅដល់ **ព្រៃនគរ** ចំណែកឯ **អង្គប៉ែន** ត្រូវយកទៅផ្លែងទឹកចោលដោយត្រូវចោទថាចង់នាំមាតារត់ទៅស្រុកសៀម ។

អំពើទាំងប៉ុន្មានដែលយួនបានប្រព្រឹត្តនេះពុំបានបាត់ស្ងាត់ទេ ។ អស់នាម៉ឺនសព្វមុខមន្ត្រី ចៅហ្វាយស្រុកខេត្តនិងអស់បណ្តារាស្ត្រកើតក្តីក្តៅក្រហាយខឹងនឹងយួន ព្រោះដឹងថាវាចំរុងនឹងរំលាយស្រុកខ្មែរអោយសាបសូន្យ ម្ល៉ោះហើយបានស្រុះចិត្តគ្នាបះឡើងកជាទ័ព លើកទៅកាប់សម្លាប់យួនអស់ជាច្រើន ។ យួនរត់មកផ្តុំគ្នានៅភ្នំពេញ ។

នាម៉ឺន និងរាស្ត្រខ្មែរជំនុំពិភាក្សា គ្នាហើយ មូលមតិគ្នាចាត់ឧកញ៉ាវិបុលរាជ **ឡុង** និងឧកញ៉ា **សួគា** លោក **មុក** អោយចូលទៅស្រុកសៀមទូលព្រះចៅ **ណាំងក្លាវ** សូមយាងព្រះ **អង្គដួង** មកគ្រប់គ្រងក្រុងកម្ពុជា ។ ព្រះចៅសៀមក៏ទ្រង់យល់ព្រមតាមសំណូមពរ ហើយចាត់ **ពញាបឌិនតេជោ** លើកទ័ពនាំព្រះ **អង្គដួង** ចូលមកស្រុកខ្មែរវិញ ។

ស្តេចយួនឃើញស្ថានការណ៍ដូច្នោះ ទ្រង់ចាត់អោយលើកទ័ពនាំព្រះមហាឧបរាជ និងក្សត្រាក្សត្រីខ្មែរមកវិញ តែរាស្ត្រខ្មែរមិនជឿយួនទៀត យួនក៏នាំព្រះមហាឧបរាជទៅគង់នៅមាត់ជ្រូកសិន ។

## ឃ. សៀមនិងយួនស្រុះស្រួលគ្នាដើម្បីត្រួតត្រាខ្មែរ

### ១. ព្រះហរិរក្សរាមាឥស្សរាធិបតីអង្គដួង (គ.ស.១៨៤០-១៨៥៩)

ព្រះ **អង្គដួង** ព្រះរាជបុត្រពៅនៃព្រះបាទ **នារាយណ៍រាជាទី ៣ អង្គអេង** ត្រូវបាននាម៉ឺនសព្វមុខមន្ត្រី និង**ពញាបឌិនតេជោ** យាងអោយឡើងគ្រងរាជសម្បត្តិ ។ ព្រះអង្គទៅគង់នៅ **វាំង ឃ្លាំងស្បែក**

ដែលរាស្ត្របានសាងថ្វាយនៅជិត **ពញាឮ** ។ ឯ **ពញាបឱនតេដោ** ក៏ស្ថិតនៅក្នុងប្រទេសខ្មែរសិនដើម្បីចាំជួយធ្វើអន្តរាគមន៍អោយបានទាន់ពេលវេលា បើមានការចាំបាច់ ។

ឯកសារយួនបាននិយាយថានៅពេលនោះ នៅប្រទេស **ចឹនឡាប**(ប្រទេសខ្មែរ) ពួកអ្នកស្រុករួមគ្នា និងពួកសៀមបានធ្វើការប្រយុទ្ធយ៉ាងខ្លាំងក្លា ។ ទ័ពយួនទប់មិនជាប់ជាហេតុនាំអោយរាជការយួនមានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ។ ម្ល៉ោះហើយនៅខាងដើមរជ្ជកាលស្តេច **ធៀវទ្រី** (១៨៤១) នាម៉ឺនឈ្មោះ **តា ក្វាង គី** (Ta quang Cu) បានទូលសុំបោះបង់ចោលប្រទេស **ចឹនឡាប** ដកថយទៅចាំទប់ទល់នៅ **មាត់ជ្រូក** វិញ ។ ស្តេចយួនទ្រង់ជឿតាមហើយបញ្ជាអោយ **ទ្រឿងមិញយ៉ាង** ដកទ័ពចេញពីស្រុកខ្មែរ ។ លុះមកដល់ មាត់ជ្រូកលោកឈឺចិត្តពេក ធ្លាក់ឈឺហើយទទួលមរណភាពទៅ (40) ។



*ព្រះបាទហរិរក្សរាមាឥស្សរាធិបតីអង្គដួង*
(រូបស្រង់ពីទស្សនាវដ្តី Le Sangkum លេខ៤ ខែវិច្ឆិកា១៩៦៥)

ប្រភពយួនដដែលនេះបាននិយាយថា ក្នុងពេលដំណាលគ្នានោះនៅស្រុកក្រោមមានការតស៊ូរបស់លោក **ឡឹមសោម** និងព្រះសង្ឃ ។ ចំពោះរឿងនេះ ឯកសារខ្លះទៀតបានបញ្ជាក់ថាលោក **ឡឹមសោម** ឬ **ធេសង្ឃសោម** បានកទ័ពនៅស្រុក **ចាបត្បើង** ក្នុងខេត្ត **ព្រះត្រពាំង** ក្នុងបំណងសងសឹកជួសចៅហ្វាយ **គុយ** និងដេញកំចាត់ពួកសត្រូវអោយចេញផុតពីទឹកដីដូនតារបស់លោក ។ ដោយមានសេនា **ឯកប្រុញ** និង **ម៉ឺនសោម** ជួយយ៉ាងសកម្មផង លោកបានលើកទ័ពទៅដល់ **ផ្លោវដូង** សម្លាប់បានយួនជាច្រើន តែនៅទីបំផុតលោកត្រូវទទួលបរាជ័យដោយទ័ពជំនួយរបស់យួនលើកមកពីខេត្តខាងកើត ។

លោកត្រូវចាប់ដាក់ទ្រុង នាំយកទៅក្រុង **វេ** ហើយត្រូវប្រហារជីវិតតាមបញ្ជាស្តេច **ធៀវទ្រី** (Thiêu-tri) ។

លុះមេទ័ពឈ្មោះ **ង្វៀង ធៀន ឡឹម** (Nguyên tiên Lâm) និង **ង្វៀង កុងទ្រី** (Nguyên công Tru) បានបង្ក្រាបការតស៊ូរបស់លោក **ឡឹមសោម** នៅស្រុកក្រោមហើយ សៀមបានលើកទ័ពជើងទឹកមកចុះត្រង់ **កំពត** ហើយការប្រយុទ្ធគ្នាជាមួយទ័ពយួន បានប្រព្រឹត្តទៅនៅ **ពាម** ។ នៅទីបំផុត សៀមដកទ័ពថយទៅវិញអស់ ។ ប៉ុន្តែទ័ពសៀមដែលនៅសល់ក្នុងស្រុកខ្មែរ និងទ័ពយួនដែលនៅក្នុងស្រុកក្រោមចេះតែប្រយុទ្ធគ្នាជាបន្តទៅទៀតរហូតដល់ឆ្នាំ ១៨៤៥ ។ នៅឆ្នាំនោះ ស្តេច **ធៀវទ្រី** បានបញ្ជាអោយ

លើកទ័ពធំចូលវាយសៀម យកបាន **ត្នោតពេញ** ហើយលើកបង្ហូសទៅព័ទ្ធក្រុង **ឧដុង្គ** ថែមទៀត ។ ខាងខ្មែរ-សៀមសុំចរចារកសន្តិភាព យួនមិនព្រម ។ តែមិនយូរប៉ុន្មាន យួនខ្លួនឯងបានសុំចរចាម្តងវិញ ។

ការចរចាបានប្រព្រឹត្តិទៅនៅសមរភូមិ **ពោធិចិដើម** : យួន និងសៀមថា ចង់ទំនុកបំរុងប្រទេសខ្មែរ និងស្តេចខ្មែរដូចគ្នា ថាត្រូវអភិសេកព្រះ **អង្គដួង** អោយឡើងសោយរាជ្យដោយតំណាងប្រទេសទាំងពីរ សៀមរុះបន្ទាយយួន យួនរុះបន្ទាយសៀម ។ សៀមបានដោះលែងមេទ័ព និងទាហានយួនជាឈ្លើយ ឯយួនត្រូវដោះលែងក្សត្រាក្សត្រីខ្មែរមកវិញ ។

រហូតដល់គ.ស.១៨៤៧ ទើបព្រះ**អង្គដួង** ត្រូវបានអភិសេកអោយឡើងសោយរាជ្យនៅ **ឧដុង្គ** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះហរិរក្សរាមាឥស្សរាធិបតី** ។ នៅឆ្នាំក្រោយ **ពញាចខិនតេជោ** បានលាព្រះអង្គត្រឡប់ចូលក្រុង **ចឹងកក** វិញ ។

គួរគប្បីជ្រាបថា នៅពេលឡើងសោយរាជ្យព្រះ **អង្គដួង** ទ្រង់តូចព្រះទ័យខ្លាំងណាស់ចំពោះការបាត់បង់ទឹកដីជាច្រើនដែលត្រូវយួន និងសៀមប្រវ័ញ្ចយកដោយខុសច្បាប់ ។ ទឹកដីខ្មែរពីដើមមានវិសាលភាពធំទូលាយ ឥលូវនេះត្រូវរួញតូចជាអតិបរិមា ប៉ុន្តែព្រះ **អង្គដួង** ពុំហ៊ានលើកយកបញ្ហានោះមកចោទ ឬតវ៉ាអ្វីជាមួយយួន និងសៀមឡើយ ពីព្រោះអ្នកជិតខាងទាំងពីរនេះមិនចូលចិត្តអោយលើកយករឿងទឹកដីនេះមកពិភាក្សាឡើងវិញ ។ គេយល់ថាទឹកដីទាំងប៉ុន្មានដែលគេបានកាន់កាប់នោះ គឺសុទ្ធតែជាកម្មសិទ្ធិស្របច្បាប់របស់គេទាំងអស់រួចហើយ ។

នៅគ.ស. ១៨៥៤ ដោយអត់ទ្រាំពុំបាននឹងអំពើរំលោភទន្ទ្រានយកទឹកដីពីសំណាក់ជនជាតិយួនដែលរស់នៅក្នុងកម្ពុជាក្រោម ព្រះ**អង្គដួង** ទ្រង់បានសំរេចព្រះទ័យថាត្រូវតែសុំជំនួយ និងការការពារពីមហាអំណាចអឺរ៉ុបណាមួយ ។ ដោយហេតុនោះ ព្រះអង្គទ្រង់បានបញ្ជូនដោយសម្ងាត់នូវមន្ត្រីខ្មែរម្នាក់កាន់សាសនាកាតូលិចអោយទៅ **សិង្ហបុរី** ដើម្បីយកព្រះសារលិខិតរបស់ព្រះអង្គសរសេរជាភាសា បារាំងដោយសម្តេច Miche យកទៅថ្វាយព្រះចៅNapoléon ទី៣ តាមរយៈលោកកុងស៊ុលបារាំងប្រចាំនៅទីនោះ ។ ជាមួយគ្នានោះព្រះ**អង្គដួង** ទ្រង់បានផ្ញើគ្រឿងបណ្ណាការខ្លះទៅថ្វាយព្រះចៅប្រទេសបារាំង មានភ្លុកដំរី កុយរមាស រង្គ ស្ករ និងម្រេចជាដើម ។ លោកកុងស៊ុលបារាំងបានសន្យាថានឹងនាំព្រះសារលិខិតនិងដង្វាយទៅក្រុងប៉ារីស ។

នៅគ.ស. ១៨៥៥ លោករាជទូត de Montigny ត្រូវបានចាត់អោយបំពេញបេសកកម្មជាច្រើននៅឥណ្ឌូចិន និងនៅប្រទេសចិន ។ លោកបានទទួលបញ្ជាពីព្រះចៅ Napoléon អោយធ្វើសន្ធិសញ្ញាមិត្តភាព និងខាងជំនួញជាមួយខ្មែរ ប៉ុន្តែការធ្វេសប្រហែសរបស់រាជទូតរូបនេះបានធ្វើអោយព្រះចៅសៀមទ្រង់ជ្រាបពីបំណងរបស់ប្រទេសបារាំង ជាហេតុបណ្តាលអោយសន្ធិសញ្ញារវាងខ្មែរ និងបារាំងពុំបានសំរេចទៅវិញ ។ ម្យ៉ាងទៀតលោក de Montigny ពុំបានអញ្ជើញទៅជួបនឹងព្រះរាជាខ្មែរទេ លោកគ្រាន់តែបញ្ជាអោយបព្វជិត Hertrest ដែលឈរនៅកំពតទៅគាល់ព្រះអង្គ ។ ដោយទ្រង់មិនពេញព្រះ

ទ័យនឹងអាកប្បកិរិយារបស់លោក Montigny ផងនិងដោយខ្លាចមានការធ្វើទុក្ខបុកម្នេញពីសំណាកសៀម ផង ព្រះ **អង្គដួង** ក៏ទ្រង់លះបង់ចោលនូវព្រះបំណងសុំការការពារពីប្រទេសបារាំង ។

ក្នុងព្រះសាលិខិតទី ២ ព្រះអង្គទ្រង់បានរំលឹកដល់ព្រះចៅ Napoléon ទឹកដីដែលយួនបានយក ហើយដែលស្ថិតនៅចន្លោះត្រើយខាងលិចនៃព្រែក **ព្រៃនគរ** និង **ពាម** គិតទាំង **កោះត្រល់** និង **កោះត្រឡាច** ពិតជាដីរបស់ខ្មែរ ។ ចំពោះព្រះសារលិខិតទី ២នេះ ប្រទេសបារាំងពុំបានឆ្លើយតបអ្វី សោះឡើយ ។

នៅគ. ស. ១៨៥៦ ដោយព្រះអង្គវ័យកាន់តែជរា ហើយដោយនឹកគិតទៅដល់អនាគតនៃប្រទេស ជាតិ ព្រះ**អង្គដួង** ទ្រង់សូមព្រះចៅសៀមអោយតែងតាំងព្រះរាជបុត្រច្បងនាម **អង្គវតី** ជាមហាឧបរាជ និងព្រះរាជបុត្របន្ទាប់នាម **ស៊ីសុវត្ថិ** ជា **ព្រះកែវហ្វា** និងសូមអោយបានវិលចូលក្រុងកម្ពុជាដើម្បី ជួយបំពេញរាជការផង ។

នាឆ្នាំដដែល យួននៅស្រុកក្រោមបានសង់បន្ទាយនៅ **ឆាយឌៅ** នៅ **ឃ្លាំង** និងនៅ **លំពូយា** ដើម្បីពង្រឹងជំហររបស់ខ្លួននៅក្នុងខេត្តខាងលិច ។ វាបានរំលោភលើអំណាចរបស់ព្រះចៅហ្វាយស្រុក **សុខ** ជាហេតុបណ្តាលអោយខ្មែរក្រោកឡើងក្រោមបញ្ជាការរបស់សេនា **លឹម** លើកទៅប្រយុទ្ធនឹង យួនដោយមានជ័យជំនះ នៅតំបន់ **ធំនប់** និង **កំពង់ត្រប់** ។ ពេលនោះព្រះ**អង្គដួង** ទ្រង់អោយសង់ បន្ទាយ និងលើកទ័ពទៅចាំនៅព្រំដែន ។ យួនឃើញដូច្នោះបានលើកទ័ពទៅវាំងដើម្បីកុំអោយខ្មែរខាង លើ និងខ្មែរខាងក្រោមទាក់ទងគ្នាបាន ។

និយាយពីនៅស្រុកយួនឯណោះ ក្នុងរជ្ជកាលរបស់ស្តេច **ទឺឌឹក** (Tu-duc) និងក្នុងរជ្ជកាលមុនៗ មានការធ្វើទុក្ខបុកម្នេញលើរូបអ្នកផ្សាយសាសនា ជាហេតុនាំអោយបារាំងធ្វើអន្តរាគមន៍យកលេសថា ដើម្បីការពារជនទាំងនោះនៅគ. ស. ១៨៥៨ ។ គឺនៅក្នុងស្ថានភាពថ្មីនេះហើយដែលព្រះ **អង្គដួង** បាន ទាក់ទងសាជាថ្មីជាមួយជនជាតិបារាំង ។ តាមរាជពង្សាវតារខ្មែរ ថាព្រះអង្គទ្រង់បានជួលទ័ពបារាំងអោយ ជួយវាយយក **ព្រៃនគរ** គិតជាឈ្នួល ៥០០ណែនប្រាក់ ។ ក្នុងពេលដំណាលគ្នានោះ ពួកចាមជ្វានៅ ខេត្ត **ត្បូងឃ្មុំ** បានបះប្រឆាំងនិងចៅហ្វាយស្រុកខេត្តនេះក្រោមការដឹកនាំមេ៣នាក់គឺ **ទួន ហ៊ីម ទួនស៊ី** និង **ទួន អ៊ិត** ។ ព្រះ**អង្គដួង** ទ្រង់លើកទ័ពទៅបង្ក្រាប មេម្នាក់ត្រូវស្លាប់ ២នាក់ទៀតបានរត់រួចចូលទៅ ខាងមាត់ជ្រូក ។

រាជពង្សាវតារខ្មែរថានៅគ. ស. ១៨៥៨នោះ លោកមេទ័ព Doudart de Lagrée បានលើកទ័ពទៅ វាយ **ព្រៃនគរ** ឯព្រះអង្គដួង ទ្រង់បញ្ជាអោយលោកឧកញ៉ាជាសេដ្ឋី **កែវ** លើកទ័ពទៅវាយ **ត្រាំង ត្បូង ឆាសាក់ ព្រះត្រពាំង ក្រមួនស មាត់ជ្រូក** ។ ចំណែកឯពួកចាមជ្វាដែលរត់ទៅ **មាត់ជ្រូក** ចូល ទៅបំបះរាស្ត្រលើកវាយ **ខុជុង្គ** តែត្រូវព្រះឧបរាជ និងព្រះកែវហ្វាចាប់បានពួកមេដឹកនាំហើយបាក់ទ័ព រត់ខ្ចាត់ខ្ចាយទៅវិញអស់ ។

និយាយពីទ័ពរបស់ឧកញ៉ា **តែម** ដែលលើកទៅវាយយួនឯស្រុកក្រោមនោះ ឃើញថាមានជោគជ័យហើយចេះតែជម្រុលទៅមុខ ប៉ុន្តែនៅពេលដែលព្រះរាជាសោយទិវង្គតទៅ(១៨៥៩) ហើយដោយមានការវឹកវរនៅឯរាជធានី **ឧដុង្គ** លោកក៏ដកទ័ពថយចូលស្រុកវិញអស់ ។ ឯកសារខ្លះបានបញ្ជាក់ថាការដែលលោកឧញ៉ា **តែម** បានលើកទ័ពចូលវាយស្រុកក្រោមនោះ គឺដើម្បីទៅបង្ក្រាបពួកចាមជ្វាបះបោររត់ទៅទីនោះ ហើយដែលរាជការយួនមិនព្រមចាប់ប្រគល់មកអោយខ្មែរវិញ (42) ។

## ២. ស្នាព្រះហស្តព្រះអង្គដួង

**ព្រះបាទហរិរក្សរាមាឥស្សរាធិបតីអង្គដួង** ជាព្រះរាជាមួយអង្គដែលប្រកបដោយទសពិធរាជធម៌ ។ ព្រះអង្គទ្រង់យកព្រះទ័យទុកដាក់រៀបចំអោយមានសន្តិភាពក្នុងប្រទេស និងអោយមានរបៀបរៀបរយក្នុងរាជការ ។ យ៉ាងណាមិញ ការបែកបាក់សាមគ្គីរវាងខ្មែរ និងចម្បាំងឈ្លានពានរបស់បរទេសជាហេតុនាំអោយប្រទេសពើបប្រទះនឹងមហន្តរាយ : ភូមិ ស្រុកត្រូវដុតបំផ្លាញ ស្រែចំការត្រូវបោះបង់ចោល ផ្លូវថ្នល់ត្រូវបំផ្លិចបំផ្លាញដោយវិច្ឆេទកម្ម និងដោយទឹកជំនន់ ស្ពានភាគច្រើនត្រូវខូចខាត ។ អសន្តិសុខកើតពាសពេញផ្ទៃប្រទេស ព្រោះរាស្ត្រដែលអត់ឃ្លានបានក្លាយទៅជាចោរលួចចោរប្លន់ កាប់សំលាប់ឥតត្រាប្រណី សកម្មភាពខាងជំនួញឥតមានទាល់តែសោះ ។

គឺនៅក្នុងស្ថានភាពដុនដាបបែបហ្នឹងហើយ ដែលព្រះ **អង្គដួង** ទ្រង់បានឡើងគ្រងរាជ្យ ។ ព្រះអង្គទ្រង់បានខិតខំរៀបចំប្រទេសជាតិឡើងវិញ និងលើកតំកើងជីវភាពប្រជារាស្ត្រ ។ រាជធានី **ឧដុង្គ** ត្រូវបានស្ថាបនាឡើងវិញ ។ ចំនួនខេត្តក្នុងព្រះរាជាណាចក្រត្រូវបន្ថយ ។ ខេត្តនីមួយៗ មានទំហំផ្ទៃប្រហាក់ប្រហែលគ្នា ហើយត្រូវបែងចែកជាស្រុក ។ ពីគ.ស. ១៨៥១ដល់ ១៨៥៧ ព្រះអង្គបញ្ជាអោយលើកផ្លូវមួយពី **ឧដុង្គ** ទៅ **កំពត** ដែលជាកំពង់ផែសមុទ្រតែមួយរបស់ខ្មែរ ព្រោះកំពង់ផែ **ព្រៃនគរ** ត្រូវបានទៅយួនជាស្ថាពរទៅហើយ ។ នៅគ.ស.១៨៥២ព្រះអង្គទ្រង់អោយលើកផ្លូវមួយទៀតភ្ជាប់រាជធានី **ឧដុង្គ** ទៅ **កំពង់ឆ្នាំង** ជាកំពង់ផែសំខាន់មួយទៀតរបស់ខ្មែរក្នុងសម័យនោះ ។

ក្នុងរជ្ជកាលរបស់ព្រះ **អង្គដួង** ព្រះអង្គបញ្ជាកុំអោយមានការតម្លើង និងការបង្កើតពន្ធថ្មី និងជៀសវាងកុំកែនរាស្ត្រអោយបំពេញកិច្ចការសាធារណៈក្នុងរដូវធ្វើស្រែចំការ ។ ព្រះអង្គមានព្រះទ័យអាណិតអាសូរចំពោះរាស្ត្រដែលរងទុក្ខវេទនា ។ ដូច្នេះហើយបានជានៅពេលដែលកើតជម្ងឺរាតត្បាតព្រះអង្គទ្រង់យាងដោយផ្ទាល់ទៅចែកស្បៀងអាហារ និងសំលៀកបំពាក់អោយរាស្ត្រក្រីក្រ ។

ម្យ៉ាងទៀត ព្រះអង្គទ្រង់ហាមមិនអោយបរបាញ់សត្វ និងមិនអោយចាប់ត្រីដោយប្រើព្រួលរាំងពេញព្រែកទេ ។ ព្រះអង្គស្តីបន្ទោស និងដាក់ទណ្ឌកម្មយ៉ាងធ្ងន់លើពួកជនប្រមឹក ជនជក់អាភៀន និងជនប្រព្រឹត្តល្បែងស៊ីសង ទ្រង់បង្ក្រាបដោយតឹងរ៉ឹងនូវអំពើចងការប្រាក់ដោយយកការធ្ងន់ហួសប្រមាណ

ហើយក្នុងការខ្ចីបុលគ្នា ទ្រង់តម្រូវអោយមានកិច្ចព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ រវាងមេបំណុល និងកូនបំណុល ។ ជាពិសេសទៅទៀត ព្រះអង្គទ្រង់បានបរិច្ចាគព្រះរាជទ្រព្យផ្ទាល់ដើម្បីលោះពួកមនុស្សខ្ញុំគេអោយបានរួចខ្លួនវិញអស់ជាច្រើន ។

ក្នុងវិស័យសេដ្ឋកិច្ច និងហេរញ្ញវត្ថុ ព្រះអង្គទ្រង់បានបោះប្រាក់រាងមូល ម្ខាងមានរូបប្រាសាទ **អង្គរវត្ត** ម្ខាងទៀតមានរូប **សត្វហង្ស** សំរាប់ប្រើប្រាស់ក្នុងព្រះរាជណាចក្រ និងទ្រង់បានទាក់ទាញឈ្មួញចិន និងឥណ្ឌា អោយចូលធ្វើពាណិជ្ជកម្មក្នុងប្រទេសខ្មែរទៀតផង ។



*ប្រាក់បោះ ក្នុងរជ្ជកាលព្រះបាទហរិរក្សរាមាឥស្សរាធិបតី អង្គដួង* (រូបស្រង់ចេញពីទស្សនាវដ្ដី Le Sangkum លេខ៤ ខែវិច្ឆិកា១៩៦៥)

ឯពន្ធដាត្រូវបានអោយទារតាមរបបភាស៊ី ជាហេតុអោយរាជការមានលទ្ធភាពរៀបចំថវិកាមួយដែលមានតុល្យភាព ។

ក្នុងវិស័យវប្បធម៌ ព្រះអង្គទ្រង់បានបង្កើតសាលាតាមវត្តជាច្រើន ទ្រង់បានលើកទឹកចិត្តពួកអ្នកប្រាជ្ញបណ្ឌិតកវី ហើយទ្រង់បាន ផ្ដល់នូវលុយកាក់ និងមធ្យោបាយផ្សេងៗដល់ជនណាដែលចង់ធ្វើការសិក្សាស្វែងរកចំណេះវិជ្ជា ។ ព្រះអង្គទ្រង់សព្វព្រះទ័យធ្វើការពិភាក្សាជាមួយព្រះសង្ឃពីបញ្ហាសាសនា និងអក្សរសាស្ត្រ និងទ្រង់បានបរិច្ចាគព្រះរាជទ្រព្យផ្ដល់ចំពោះព្រះសង្ឃ សំរាប់កសាងវត្តអារាម និងចំណាយផ្សេងៗ តាមព្រះពុទ្ធបញ្ញត្តិ ។

នៅទីបញ្ចប់នេះ គួគប្បីបញ្ជាក់ដែរថា ព្រះ**អង្គដួង** ជាអ្នកនិពន្ធមួយរូបយ៉ាងឆ្នើមដែរ ។ ស្នាព្រះហស្តរបស់ព្រះអង្គក្នុងវិស័យអក្សរសិល្ប៍គឺ :

- **ចម្បាំងថោង** (គ.ស. ១៨១០)
- **រឿងកាកី** (គ.ស. ១៨១៥)
- **ច្បាប់ស្រី** (គ.ស. ១៨៣៧) (30) ។

# បញ្ជីឯកសារពិគ្រោះ


1. Henri Marchal, Angkor, Paris, 1955

2. Revue France-Asie, nº spécial pour la civilisation khmère, Saigon, 1955

3. ឯកសារមហាបុរសខ្មែរលេខ៤ បោះពុម្ពផ្សាយដោយលោកអេងសុតនៅភ្នំពេញគ. ស. ១៩៦៩

4. លោកកងគីរី-លោកសែមសូរ : ប្រជុំអនុពាក្យទំនើប ទំព័រ ៨៤ -កំពង់ចាម-១៩៦៣ ។

5. សម្ដេចព្រះមហាសុមេធាធិបតី ជួនណាត-ប្រវត្តិនៃវត្តឧណ្ណាលោម-ភ្នំពេញ គ. ស. ១៩៥៣ ។

6. លោកស៊ឹមវ៉ា និងលោកលីអេង - ប្រវត្តិនៃប្រទេសកម្ពុជា (សាកល្បង) បោះពុម្ពហើយ តែមិនបានផ្សាយនៅភ្នំពេញ គ. ស. ១៩៦៩ ។

7. Etienne Aymonier, Le Cambodge , tome III, Paris, 1904.

8. បែបរៀនសង្គមសិក្សា វិជ្ជាប្រវត្តិសាស្ត្រថ្នាក់មធ្យមសិក្សាឆ្នាំទី១ របស់ក្រុមវិជ្ជាការក្រសួងសិក្សាធិការ (ភាសាថៃ) បឹងកក -ព. ស. ២៥១២ គ. ស. ១៩៦៨ ។

9. Dauphin Meunier, Histoire du Cambodge, PUF , Que sais -je ? Paris 1961.

10. -12- Henri Russier, Histoire sommaire du royaume du Cambodge des origines à nos jours (brochure ronéotypée), 1929 ?

11. Adhémard Leclère, le Sdach Kân, Imprimerie coloniale, Saigon, 1911.

13. Lê Thanh Khôi, Histoire de l'Asie du Sud - est, PUF , Que sais-je ? Paris, 1959.

14. B.P. Groslier, Angkor et le Cambodge au 16º siècle d'après les sources portugaises et espagnoles, Paris, 1958.

15. France- Asie, nº spécial 118-119, Présence du Royaume lao, Saigon. 1956.

16. ពង្សាវតារប្រទេសលាវ គឺក្រុងហ្លួងព្រះបាង ក្រុងវៀងចន្ទ ក្រុងជួន និងក្រុងចំប៉ាស័ក (ជាភាសាលាវ) - វៀងចន្ទ គ. ស. ១៩៦៧ ។ Annales de Laos-Luang Prabang- Vientiane - Tranninh et Bassac, publiées la 22e année du règne de S.M. Sisavang Vong Roi du Luang Prabang, 1926.

17. ឯកសារមហាបុរសខ្មែរ លេខ ២៧-២៨ របស់លោកអេងសុត បោះពុម្ពផ្សាយនៅក្រុងភ្នំពេញ នៅគ. ស. ១៩៦៩ ។

18. ប្រវត្តិវិទ្យា ភាគ ១ ថ្នាក់ទី ១ - ខេមរយានកម្ម - ភ្នំពេញ - ១៩៧២ ។

19. Lawrence Palmer Priggs, Les missionnaires portugais et espagnols au Cambodge (1555-1603), texte traduit de l'anglais par Monique Dupont et publié dans Fullectin de la Société des Etudes Indochinoises (Nouvelle série - Tome xxv, n° 1-1er trimestre 1950), Saigon, 1950.

20. H. Sutton, Singapore in history, federal publications, Singapore, 1967.

21. ព្រះរាជពិធីទ្វាទសមាស ភាគ ១ បោះពុម្ពលើកទី ២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០០ - គ.ស.១៩៥៦ ។

22. J. Imbert, Histoire des Institutions Khmères, volume II, Annales de la Faculté de Droit de Phnom Penh, 1961.

23. លោកអនុសេនីយឯក សឺននី - ប្រវត្តិយោធាខ្មែរ អត្ថបទផ្សាយតាមទូរទស្សន៍សាធារណរដ្ឋខ្មែរ ខែ មេសា ១៩៧៤ ។

24. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៦ - ភ្នំពេញ ១៩៦៩ ។

25. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត-លេខ ១២-១៦-១៨ ភ្នំពេញ ១៩៦៩ ។

26. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៧ - ភ្នំពេញ គ.ស. ១៩៦៩ ។

27. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ១៥ - ភ្នំពេញ គ.ស. ១៩៦៩ ។

28. សិលាចារឹកនគរវត្ត និងបទានុក្រម - ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ គ.ស. ១៩៥៨ ។

29. គោលប្រវត្តិសាស្ត្រនៃអក្សរសាស្ត្រខ្មែរ ដោយប្រជុំសាស្ត្រាចារ្យ- ការផ្សាយរបស់បណ្ណាគារភ្នំពេញ - ភ្នំពេញ គ.ស. ១៩៥៦ ។

30. លោក ឃួន សុខម្ភូ - គំនិតរិះគន់សង្គមក្នុងអក្សរសិល្ប៍ខ្មែរ - សន្និសីទធ្វើនៅសាលាជាតិខាងរដ្ឋបាល នៅថ្ងៃទី ១ មិថុនា ១៩៧៤ នៅភ្នំពេញ ។

31. L'organisation buddhique au Cambodge, n°4 , Série Cuture et Civilisation Khmères, Phnom Penh, 1963.

32. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ២២ - ភ្នំពេញ គ.ស. ១៩៦៩ ។

33. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ២៣ - ភ្នំពេញ គ.ស. ១៩៦៩ ។

34. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៧ - ភ្នំពេញ គ.ស. ១៩៦៩ ។

35. Madeleine Giteau, Depuis un siècle, un effort soutenu pour dégager et restaures Angkor, dans SOS Angkor, Courrier de L'Unesco, Décembre 1961.

36. ប្រជុំពង្សាវតារ ច្បាប់បណ្ណាល័យជាតិ- ក្បាលទី១ - រោងពុម្ពការវហ្នា បោះពុម្ពលើកដំបូង - ក្បាលទី ១ ឧសភា ព.ស.២៥០៦ ( ជាភាសាថៃ) ។

37. Phan Khoang, Viêt Su : Xu Dang Trong 1558-1777, Saigon, 1969.

38. Lê Huong, Su Cac Miên, Saigon, 1970.

39. Charles Meyer, Phnom Penh, à la recherche du passé - les premiers occidenteaux à Phnom Penh, article publié dans Nokor Khmer, n°2, Phnom Penh, 1970.

40. Tran Trong Kim, Vietnam Su Luoc, Sagon, 1964.

41. G. Nandin, Histoire de la Cochinchine.

42. Jean Moura, Le Royaume du Cambodge, Paris, 1883.

43. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៦៤ - ភ្នំពេញ គ.ស.១៩៦៩ ។

44. Adhémard Leclère, l'Histoire du Cambodge, Geuthner, Paris, 1914.

45. Lê Huong, Nguoi Viet gôc Miên, Sagon, 1969.

46. P. Schweisguth, un siècle d'histoire dans la péninsule indochinoise (1750-1850), Imprimerie Taupin et , Hanôi, 1944.

47. លោក កែវសុវត្ថិ - ថៅហ្វាយគុយ - ភ្នំពេញ - ១៩៧១ ។

48. Gérard Groussin,,Le protectorat Français sur le Cambodge de 1863 à 1884 (ronéotypé), Centre de documentation et de recherche de la Faculté des Lettres et des Sciences humaines de Phnom Penh, 1973.

49. Luang vichitr Vadakarn, Thailand's case, Bangkok, 1941.

50. Charles Meyer, Insurrections nationales du siècle dernier, dans Etudes cambodgiennes n° 9 , Phnom Penh, 1967.

51. M. Giteau, Histoire du Cambodge, Didier, Paris, 1957.

52. លោក ឌឹកគាម - អាចារ្យស្វា - ភ្នំពេញ គ.ស. ១៩៧៣ ។

53. La monarchie khmère, dans le Sangkum nº 5, décembre 1965, Phnom Penh.

54. L'histoire de Kralahom Kong par ImChhum (traduction libre Suon On et Charles Meyer), dans Etudes cambodgiennes nº 18, Phnom Penh, 1969.

55. Gaston Barrault, Cambodgiens de Cochinchine, Editions de la Revue Extrême - Orient, Saigon, 1927.

56. La frontière Khméro - vietnamienne, dans Etudes Cambodgiennes nº 7 Phnom Penh, 1966.

57. Sarin Chhak, Quelques faits historiques sur le tracé des frontières entre le Cambodge, le Laos et le Vietnam ចុះផ្សាយក្នុងទស្សនាវដ្ដីសាស្ត្រចារ្យ លេខ ១៤- ឆ្នាំទី ៥- ១៩៦៤ ។

58. La monarchie khmère, dans le Sangkum nº 6, Phnom Penh, 1966.

59. Ho Tong Peng, L'économie de l'hévéaculture en 1965, dans Etudes cambodgiennes nº 1, Phnom Penh, 1965.

60. លោក ឌឹកគាម និងលោក ឌៀកអំ - ភូមិគីរិថ្លាន - ភ្នំពេញ -គ.ស. ១៩៧១ ។

61. L'oeuvre de Sa Majesté Monivong, dans le Sangkum nº 8 Phnon Penh, 1966.